ក

## មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


២៧-១២-២០០៨ -ព្រះរាជក្រម នស/រកម/១២០៨/០២០ ស្ដីពីការប្រកាសអោយប្រើច្បាប់ស្ដីពី ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០០៩ ០១


### ២~ព្រះរាជក្រឹត្យ


២៧-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៤១៤ ស្ដីពីការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **យូ ជែឈិន** (YOO JAE CHUN) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅ ក្រុងខ្យ៉ុងគីដូ ខេត្តហ្គាផ្យង់ សាធារណរដ្ឋកូរ៉េ ៤៩

២៧-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៤១៥ ស្ដីពីការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **ជូ យីតវ៉ា** (CHU YUET WAH) ជនជាតិចិន សញ្ជាតិចិន កើតនៅ ក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ៥០

២៧-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៤២០ ស្ដីពីការតែងតាំង ឯកឧត្តម ឧត្តមសេនីយ៍ទោ **ឡើន សុវណ្ណ** ជាប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ រដ្ឋលេខាធិការ ៥១

២៧-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៤២១ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ជូនចំពោះនាយទាហានជាន់ខ្ពស់ ចំនួន ១៨ រូប ៥២

២៧-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៤២២ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេរីវឌ្ឍន៍ ចំពោះឯកឧត្តម **លី គីមឡុង** ៥៣

២៧-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៤២៣ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ នាយទាហានជាន់ខ្ពស់ ចំនួន០៤រូប ៥៤

២៧-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៤២៤ ស្ដីពីការប្រោសព្រះរាជទានចំពោះ ឯកឧត្តម ឧត្តមសេនីយ៍ទោ **ឡឿន ជុនធូ** នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់មហាសេរី វឌ្ឍន៍ ៥៥

២៩-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៤២៥ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម.លោកឧកញ៉ា និងអស់លោក ចំនួន ៣៨ រូប ៥៦

២៩-១២-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៤២៦ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម,លោក និងលោកស្រី ចំនួន ១៨ រូប ៥៨

៣១-១២-២០០៨-ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៤២៧ ស្តីពីការតម្លើងឋានន្តរស័ក្តិ ក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ជាកិច្ចបច្ឆាមរណៈ ជូនសពលោក **ម៊ុន ហោ** ឋានន្តរស័ក្តិវរមន្ត្រីថ្នាក់លេខ ៦ ទៅជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ ៥៩

៣១-១២-២០០៨-ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៤២៨ ស្តីពីការប្រោសព្រះរាជទានជាកិច្ចបច្ឆាមរណៈ ចំពោះសពលោក **ម៊ុន ហោ** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ៦០

៣១-១២-២០០៨-ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៤២៩ ស្តីពីការបង្កើត "គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ " ដែលមានឈ្មោះជាអក្សរកាត់ថា "គ.ជ.អ.ប" ដើម្បីសម្របសម្រួលដឹកនាំការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងការអនុវត្តគោល នយោបាយ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ៦១

៣១-១២-២០០៨-ព្រះរាជក្រឹត្យ នស/រកត/១២០៨/១៤៣០ ស្តីពីការតែងតាំង ឯកឧត្តម **ហង់ ពៅ** ជាអគ្គ នាយករង នៃអគ្គនាយកដ្ឋានអាជ្ញាធរអប្សរា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៧២

០២-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០០១ ស្តីពីការតែងតាំងទីប្រឹក្សាក្រសួងព័ត៌មាន ចំនួន ០២ រូប មានឋានៈស្មើអគ្គនាយក ៧៤

០២-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០០២ ស្តីពីការតែងតាំងលោកជំទាវ **លី វួចឡេង** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា និងជាអនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ មានឋានៈស្មើ រដ្ឋមន្ត្រី ៧៥

០២-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០០៣ ស្តីពីការតែងតាំងទីប្រឹក្សាក្រសួងផែនការ ចំនួន ០៤ រូប មានឋានៈស្មើអនុរដ្ឋលេខាធិការ ៧៦

០២-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០០៤ ស្តីពីការតែងតាំងមន្ត្រីរាជការ ចំនួន ១០ រូប នៃឧត្តម ក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងតម្លើងឋានៈស្មើ អគ្គនាយក ជូនមន្ត្រីរាជការ នៃឧត្តមក្រុមប្រឹក្សា សេដ្ឋកិច្ចជាតិ ចំនួន ០២ រូប ៧៧

០២-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០០៥ ស្តីពីការតែងតាំងលោកជំទាវ **ខៀវ សិរីវុឌ្ឍា** ជា អគ្គនាយក នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី ៧៩

**គ**

០២-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០០៦ ស្តីពីការតែងតាំងលោកជំទាវ ជាទីប្រឹក្សា ឯកឧត្តម **ខួន ញ៉ិល** អគ្គនាអនុប្រធានទី ១ រដ្ឋសភា នីតិកាលទី ៤ ចំនួន ០២ រូប ៨០

០៤-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០០៧ ស្តីពីការតែងតាំងឯកឧត្តម **កែវ ពុទ្ធរស្មី** ជាទីប្រឹក្សា រាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជាមានឋានៈស្មើឧបនាយករដ្ឋមន្ត្រី ៨១

# ព្រះរាជក្រម

នស/រកម/១២០៨/០២០

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជនរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ដែលរដ្ឋសភាបាន អនុម័តកាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី ១ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៥ នីតិកាលទី ២ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់

# ស្តីពី

# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង

# ឆ្នាំ ២០០៩

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

# ជំពូកទី ១

# ចំណូល_ចំណាយនៃថវិកាទូទៅរបស់រដ្ឋ

**មាត្រា ១.–**

ត្រូវបានអនុញ្ញាតសម្រាប់ឆ្នាំ ២០០៩ ឱ្យប្រមូលបង់ចូលថវិកាទូទៅរបស់រដ្ឋនូវពន្ធ-ដារ វិភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឱ្យសម្រេចនូវអំណោយមូលនិធិឧបត្ថម្ភនិងធនធានបានមកពីការខ្ចីតាមមាតិកាថវិកា ដូចមានចែងក្នុងតារាង “ក” ដែលភ្ជាប់មកជាមួយច្បាប់នេះក្នុងទឹកប្រាក់សរុបចំនួន ៧.២៥៩.៥៦៦,៧ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ :

-ចំណូលចរន្ត..........................៥.០៨៦.៥៦៦,៧ លានរៀល

-ចំណូលមូលធន........................២.០៨៣.០០០ លានរៀល

+ ចំណូលមូលធនក្នុងប្រទេស...............៤៨.០០០ លានរៀល

+ ចំណូលមូលធនក្រៅប្រទេស........២.០៣៥.០០០ លានរៀល

-ប្រើប្រាស់បញ្ញើរាជរដ្ឋាភិបាល.................៩០.០០០ លានរៀល

**មាត្រា ២.–**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានសម្រាប់ចំណាយក្នុងថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ត្រូវបានកំណត់ស្មើនឹង ៧.២៥៩.៥៦៦,៧ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ :

-ចំណាយចរន្ត.........................៤.៣៦១.០៦៦,៧ លានរៀល

-ចំណាយមូលធន........................២.៨៩៨.៥០០ លានរៀល

❖ វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

.......................................១.១៩៨.៥០០ លានរៀល

+ ដោយមូលនិធិថវិកា...............៧៧៣.៥០០ លានរៀល

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

-គម្រោងវិនិយោគផ្ទាល់............៤៤៨.៥០០ លានរៀល

-បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស

..............................១៨៥.០០០ លានរៀល

-ការទូទាត់ប្រាក់កម្ចី...............១៤០.០០០ លានរៀល

+ ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍

...................................៤២៥.០០០ លានរៀល

❖ វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

...................................១.៧០០.០០០ លានរៀល

**មាត្រា ៣.–**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានថវិកាសម្រាប់ចំណាយចរន្តរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ត្រូវបានកំណត់ស្មើនឹង ៤.៣៦១.០៦៦,៧ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និង តាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និង ទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង “ខ” ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៤.–**

ចំនួនទឹកប្រាក់នៃឥណទានវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់ការគ្រប់គ្រងពីឆ្នាំ ២០០៩ ដល់ ២០១១ ត្រូវបានកំណត់ស្មើនឹង ៨.៤៣៨.២៩៦ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗនិងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗតាមគម្រោងនិងតាមឆ្នាំ ដូចមានចែងក្នុងតារាង “គ១-គ២-គ៣” ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

Kel

**មាត្រា ៥.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យានិងឥណទានទូទាត់សម្រាប់ចំណាយជាមូលធននៃថវិការដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ត្រូវបានកំណត់ដូចខាងក្រោម :

-ឥណទានភ្ជាប់សន្យា....................៣.៦២៣.១០០ លានរៀល

-ឥណទានទូទាត់.........................២.៨៩៨.៥០០ លានរៀល

ឥណទាននេះត្រូវបានបែងចែកដូចតទៅ :

ក.វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស :

-ឥណទានភ្ជាប់សន្យា.....................១.០៥៨.៥០០ លានរៀល

-ឥណទានទូទាត់..........................១.០៥៨.៥០០ លានរៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស :

-ឥណទានភ្ជាប់សន្យា.....................២.៤២៤.៦០០ លានរៀល

-ឥណទានទូទាត់..........................១.៧០០.០០០ លានរៀល

គ. ការទូទាត់ប្រាក់កម្ចី :

-ឥណទានភ្ជាប់សន្យា........................១៤០.០០០ លានរៀល

-ឥណទានទូទាត់.............................១៤០.០០០ លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗនិងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងតាមជំពូកថវិកាដូចមានចែងក្នុងតារាង “ឃ” ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៦.-**

តុល្យភាពនៃថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ដែលបានរៀបចំឡើងដោយតារាង “ក” ស្តីពីចំណូលថវិកាទូទៅរបស់រដ្ឋ និងតារាង “ខ” ស្តីពីចំណាយថវិកាទូទៅរបស់រដ្ឋ ត្រូវបានបង្ហាញនៅក្នុងតារាងនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋដូចតទៅ :

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

KH

ឯកតា : លានរៀល

| កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ | ចំនួនទឹកប្រាក់ | ចំនួនលើស(+) /ឱនភាព(-) |
|---|---|---|
| I. ចំណូលក្នុងប្រទេស | ៥.១៣៤.៥៦៦,៧ | |
| ១. ចំណូលចរន្ត | ៥.០៨៦.៥៦៦,៧ | |
| ២. ចំណូលមូលធនក្នុងប្រទេស | ៤៨.០០០ | |
| II. សរុបចំណាយថវិកា | ៧.១១៩.៥៦៦,៧ | |
| ១. ចំណាយចរន្ត | ៤.៣៦១.០៦៦,៧ | |
| ២. ចំណាយមូលធន (មិនគិតការទូទាត់ប្រាក់កម្ចី) | ២.៧៥៨.៥០០ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ១.០៥៨.៥០០ | |
| - ដោយមូលនិធិថវិកា | ៦៣៣.៥០០ | |
| + គម្រោងវិនិយោគផ្ទាល់ | ៤៤៨.៥០០ | |
| + បដិភាគ | ១៨៥.០០០ | |
| - វិនិយោគដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទាន ដោយដៃគូអភិវឌ្ឍន៍ | ៤២៥.០០០ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ១.៧០០.០០០ | |
| អតិរេកនៃថវិកាចរន្ត ( I.១ -II.១ ) | | +៧២៥.៥០០ |
| ឱនភាពសរុបនៃថវិកាទូទៅ (I-II ) | | -១.៩៨៥.០០០ |
| III. ហិរញ្ញប្បទាននៃឱនភាព | | +១.៩៨៥.០០០ |
| ១. ហិរញ្ញប្បទានក្រៅប្រទេស | | +១.៨៩៥.០០០ |
| - មូលនិធិទ្រទ្រង់ថវិកា | | +៣៣៥.០០០ |
| - មូលនិធិវិនិយោគសាធារណៈដោយហិរញ្ញប្បទាន ក្រៅប្រទេស | | +១.៧០០.០០០ |
| - ការទូទាត់ប្រាក់កម្ចី | | -១៤០.០០០ |
| ២. ហិរញ្ញប្បទានក្នុងប្រទេស | | +៩០.០០០ |
| - បញ្ញើរាជរដ្ឋាភិបាល | | +៩០.០០០ |

# ជំពូកទី ២
# ការខ្ចីនិងការធានារបស់រដ្ឋ

## មាត្រា ៧.-

អនុម័តយល់ព្រមឱ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេមានកម្រិតរហូតដល់ ២០០.០០០.០០០ S.D.R (ពីររយលានអេសដេអ៊ែ) សម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកម្រិតខាងលើត្រូវមានលក្ខណៈជាការខ្ចីសម្បទានដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ ។

នៅក្នុងលក្ខខណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលក្នុងការចុះហត្ថលេខាលើការខ្ចីជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬ លើការធានារបស់រដ្ឋ ហើយត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តនៃការខ្ចីនិងការធានានេះ ជូនរដ្ឋសភា និងព្រឹទ្ធសភារៀងរាល់ ៦ ខែម្តង ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការឯកភាពពីធនាគារជាតិនៃកម្ពុជា ត្រូវបានទទួលការអនុញ្ញាតឱ្យបោះផ្សាយបណ្ណរតនាគារក្នុងកម្រិតទឹកប្រាក់ដែលមានស្តុកចំនួន ១០០.០០០.០០០.០០០ ៛ (មួយរយពាន់លានរៀល) ដើម្បីដោះស្រាយនូវតម្រូវការជាបន្ទាន់ខាងសាច់ប្រាក់ ។ លក្ខខណ្ឌនៃការលក់បណ្ណរតនាគារនេះត្រូវកំណត់ដោយលិខិតបទដ្ឋានស្របច្បាប់ ។

## មាត្រា ៨.-

មិនអនុញ្ញាតឱ្យក្រសួងឬស្ថាប័នសាធារណៈណាមួយចំណុះរដ្ឋ មានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលបត្ររយៈពេលវែង មធ្យម ខ្លី ឬ ឥណទានអ្នកផ្គត់ផ្គង់ ឬ ចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬ ការធានាកិច្ចសន្យាដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈ ឬ ឯកជន ឬ ចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែល

ត្រូវសងបំណុលតាមកាលកំណត់ឬតាមឆ្នាំដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញ-វត្ថុ និងលក្ខខណ្ឌទាំងឡាយ ដែលច្បាប់នេះបានកំណត់នោះទេ ។

## ជំពូកទី ៣
## និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការ
## ចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៨

**មាត្រា ៩.-**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ត្រូវបានយល់ព្រមជាគោលការណ៍ផ្តល់ឥណទានថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ចំនួនទឹកប្រាក់ ១៩៧.០០០ លានរៀលក្នុងនោះ :

-សម្រាប់ការងារប្រាសាទព្រះវិហារចំនួន ១០០.០០០ លានរៀល ។

-សម្រាប់ឧបត្ថម្ភកធនដល់អគ្គិសនីកម្ពុជាក្នុងការដោះស្រាយការធ្វើអាជីវកម្ម និងវិនិយោគក្នុងឆ្នាំ ២០០៨ របស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ទឹកប្រាក់ចំនួន ៩៧.០០០ លានរៀល ។

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៨ នឹងត្រូវអនុម័តនូវចំនួនទឹកប្រាក់ជាក់ស្តែងនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមខាងលើនេះ ។

## ជំពូកទី ៤
## ថវិការបស់ខេត្ត-ក្រុង សម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩

**មាត្រា ១០.-**

យោងច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ និងដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ១៨ថ្មីនៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិង

ទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលមានចែងនៅក្នុងមាត្រា៦នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ កញ្ចប់ថវិការួមនៃថវិការបស់ខេត្ត-ក្រុង សម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ត្រូវបានកំណត់ដូចខាងក្រោមនេះ :

សរុបចំណូលថវិកា.............................៣៥៦.៩៥០ លានរៀល

-សរុបចំណូលចរន្ត..........................២៩១.៩៥០ លានរៀល

\+ ចំណូលសារពើពន្ធ...................២៧២.១២៧ លានរៀល

\+ ចំណូលមិនមែនសារពើពន្ធ.............១៩.៨២៣ លានរៀល

-ចំណូលមូលធន.....................................០ លានរៀល

\+ ចំណូលមូលធនផ្ទៃក្នុង............................០ លានរៀល

-ចំណូលឧបត្ថម្ភពីថវិការដ្ឋ...............៦៥.០០០ លានរៀល

សរុបចំណាយថវិកា...........................៣៥៦.៩៥០ លានរៀល

-ចំណាយចរន្ត..............................២៤៥.៨៣៩ លានរៀល

-ចំណាយមូលធន...................១១១.១១១ លានរៀល

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមខេត្ត-ក្រុងនីមួយៗក៏ដូចជាការបែងចែកឥណទាននៅផ្ទៃក្នុងថវិកាជាជំពូក គណនី និងអនុគណនី ត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

KH

**មាត្រា ១២.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ២០០៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រល.០៩១២.១៤២២

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខៈ ១៣៧០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ីម ជិនកេន**

# ការគ្រប់គ្រងឆ្នាំ ២០០៩

## តារាង "ក"

## ចំណូលថវិកាទូទៅរបស់រដ្ឋ

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ២០០៩/២០០៨ | |
|---|---|---|---|---|---|---|---|
| | | | | ២០០៨ | ២០០៩ | កើន (+) / ថយ (-) | ភាគរយ |
| | | | **សរុបរួមចំណូលថវិកា ( I + II )** | **5.608.316,7** | **7.169.566,7 *** | **1.561.250,0** | **27,8%** |
| | | | **I. សរុបចំណូលឆ្លងកាត់តេនាគារជាតិ (ក+ខ)** | **4.208.316,7** | **5.469.566,7** | **1.261.250,0** | **30,0%** |
| | | | **ក្នុងនោះ ចំណូលក្នុងប្រទេស** | **3.986.916,7** | **5.134.566,7** | **1.147.650,0** | **28,8%** |
| | | | **ក. សរុបចំណូលចរន្ត (ក្រ១+ក្រ២)** | **3.886.916,7** | **5.086.566,7** | **1.199.650,0** | **30,9%** |
| | | | **ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២)** | **3.886.916,7** | **5.086.566,7** | **1.199.650,0** | **30,9%** |
| | | | **ប្រភេទទី១: ចំណូលសារពើពន្ធ** | **3.306.846,4** | **4.276.947,7** | **970.101,3** | **29,3%** |
| **70** | | | **ចំណូលសារពើពន្ធក្នុងប្រទេស** | **2.358.822,4** | **3.154.467,7** | **795.645,3** | **33,7%** |
| | 700 | | ពន្ធលើផលទុន ប្រាក់ចំណេញ និងកំរៃទុន (រូបវន្តបុគ្គល) | 91.400,0 | 147.216,0 | 55.816,0 | 61,1% |
| | | 7001 | ពន្ធលើប្រាក់បៀវត្ស | 68.000,0 | 111.416,0 | 43.416,0 | 63,8% |
| | | 7002 | ពន្ធលើផលទុននៃដីធ្លីផ្ទះសំបែង | 23.400,0 | 35.800,0 | 12.400,0 | 53,0% |
| | 701 | | ពន្ធលើផលទុន ប្រាក់ចំណេញ និងកំរៃទុន (នីតិបុគ្គល) | 394.600,0 | 599.190,0 | 204.590,0 | 51,8% |
| | | 7011 | ពន្ធលើប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ | 32.000,0 | 45.000,0 | 13.000,0 | 40,6% |
| | | 7012 | ពន្ធលើប្រាក់ចំណេញសហគ្រាសឯកជន | 360.000,0 | 550.070,0 | 190.070,0 | 52,8% |
| | | 7013 | ពន្ធលើផលទុននៃដីធ្លីផ្ទះសំបែង | 2.600,0 | 4.120,0 | 1.520,0 | 58,5% |
| | 702 | | ពន្ធទូទៅលើទ្រព្យសម្បត្តិ និងសេវា | 1.163.724,0 | 1.578.967,0 | 415.243,0 | 35,7% |
| | | 7021 | អាករលើផលរបរ-របបផ្ទៃក្នុង (សហគ្រាសសាធារណៈ) | 5,0 | | -5,0 | -100,0% |
| | | 7022 | អាករលើផលរបរ-របបផ្ទៃក្នុង (សហគ្រាសឯកជន) | 13.995,0 | 15.360,0 | 1.365,0 | 9,8% |
| | | 7023 | អាករលើតំលៃបន្ថែម-របបផ្ទៃក្នុង (សហគ្រាសសាធារណៈ) | 19.500,0 | 23.150,0 | 3.650,0 | 18,7% |
| | | 7024 | អាករលើតំលៃបន្ថែម-របបផ្ទៃក្នុង (សហគ្រាសឯកជន) | 440.500,0 | 710.777,0 | 270.277,0 | 61,4% |
| | | 7025 | អាករលើតំលៃបន្ថែម-របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 144.024,0 | 199.680,0 | 55.656,0 | 38,6% |
| | | 7026 | អាករលើតំលៃបន្ថែម-របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 545.700,0 | 630.000,0 | 84.300,0 | 15,4% |
| | 703 | | ពន្ធលើទ្រព្យសម្បត្តិបានកំណត់ | 587.952,0 | 657.940,0 | 69.988,0 | 11,9% |
| | | 7031 | អាករពិសេសលើទំនិញមួយចំនួន-របបផ្ទៃក្នុង | 95.700,0 | 120.100,0 | 24.400,0 | 25,5% |
| | | 7032 | អាករពិសេសលើទំនិញមួយចំនួន-របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 161.772,0 | 182.400,0 | 20.628,0 | 12,8% |
| | | 7033 | អាករពិសេសលើទំនិញមួយចំនួន-របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 330.480,0 | 355.440,0 | 24.960,0 | 7,6% |
| | 704 | | អាករលើសេវាដែលបានកំណត់ | 113.344,0 | 155.106,0 | 41.762,0 | 36,8% |
| | | 7041 | អាករលើកាស៊ីណូ | 68.500,0 | 77.063,0 | 8.563,0 | 12,5% |
| | | 7042 | អាករលើឆ្នោត | 2.900,0 | 3.262,0 | 362,0 | 12,5% |
| | | 7043 | អាករលើល្បែងភ្នាល់ផ្សេងៗ | 4.644,0 | 5.224,0 | 580,0 | 12,5% |
| | | 7048 | អាករពិសេសលើសេវាមួយចំនួនផ្សេងៗទៀត | 37.300,0 | 69.557,0 | 32.257,0 | 86,5% |
| | 705 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិ ឬ ការអនុវត្តសកម្មភាព | 802,4 | 1.398,7 | 596,3 | 74,3% |
| | | 7052 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | 802,4 | 1.398,7 | 596,3 | 74,3% |
| | 708 | | ចំណូលសារពើពន្ធផ្សេងៗទៀត | 7.000,0 | 14.650,0 | 7.650,0 | 109,3% |
| | | 7081 | ពន្ធតែមប្រិ៍ | 2.600,0 | 3.500,0 | 900,0 | 34,6% |

* សរុបរួមចំណូលថវិកាឆ្នាំ ២០០៩ នេះ មិនទាន់គិតបញ្ចូលការប្រើប្រាស់បញ្ញើរាជរដ្ឋាភិបាលទេ

# ការគ្រប់គ្រងឆ្នាំ ២០០៩

## តារាង "ក"

## ចំណូលថវិកាចរន្តរបស់រដ្ឋ

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ២០០៩/២០០៨ | |
|---|---|---|---|---|---|---|---|
| | | | | ២០០៨ | ២០០៩ | កើន (+) / ថយ (-) | ភាគរយ |
| | | 7082 | ការផាកពិន័យ និង ទោសបញ្ញត្តិសារពើពន្ធ | 4.400,0 | 11.150,0 | 6.750,0 | 153,4% |
| **71** | | | **ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស** | **948.024,0** | **1.122.480,0** | **174.456,0** | **18,4%** |
| | 710 | | ពន្ធ និងអាករលើការនាំចូល | 835.584,0 | 999.600,0 | 164.016,0 | 19,6% |
| | | 7101 | ពន្ធគយពីការនាំចូល | 487.152,0 | 541.200,0 | 54.048,0 | 11,1% |
| | | 7102 | កំរៃយកមុនពីការងារគយក្នុងការនាំចូល | 63.444,0 | 60.720,0 | -2.724,0 | -4,3% |
| | | 7103 | ពន្ធគយលើផលិតផលគេលសិលា | 178.296,0 | 238.800,0 | 60.504,0 | 33,9% |
| | | 7104 | អាករបន្ថែមលើផលិតផលគេលសិលាសំរាប់ថែទាំផ្លូវថ្នល់ | 101.796,0 | 150.480,0 | 48.684,0 | 47,8% |
| | | 7105 | ផលនៃការលក់ផ្នែកគយ | | 480,0 | 480,0 | !!! |
| | | 7106 | ពិន័យផ្សេងៗលើការនាំចូល | 4.896,0 | 7.920,0 | 3.024,0 | 61,8% |
| | 711 | | ពន្ធ និង អាករលើការនាំចេញ | 112.440,0 | 122.880,0 | 10.440,0 | 9,3% |
| | | 7111 | អាករលើការនាំចេញឈើ | 3.060,0 | 4.320,0 | 1.260,0 | 41,2% |
| | | 7112 | អាករលើការនាំចេញកៅស៊ូ | 16.524,0 | 24.960,0 | 8.436,0 | 51,1% |
| | | 7114 | អាករលើការនាំចេញផលិតផល និងកសិផលផ្សេងៗ | 2.652,0 | 3.360,0 | 708,0 | 26.7% |
| | | 7115 | កំរៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | 90.000,0 | 90.000,0 | | |
| | | 7116 | ពិន័យផ្សេងៗលើការនាំចេញ | 204,0 | 240,0 | 36,0 | 17,6% |
| **ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ** | | | | **580.070,3** | **809.619,0** | **229.548,7** | **39,6%** |
| **72** | | | **ផលមុននៃទ្រព្យសម្បត្តិរដ្ឋ** | **76.459,0** | **124.785,1** | **48.326,1** | **63,2%** |
| | 720 | | ផលនៃសម្បទាន និងការជួលដីធ្លី | 29.295,0 | 36.575,4 | 7.280,4 | 24,9% |
| | | 7201 | សម្បទានទេសាទ | 8.750,0 | 8.965,0 | 215,0 | 2,5% |
| | | 7202 | សម្បទានព្រៃឈើ | 10.000,0 | 11.212,0 | 1.212,0 | 12,1% |
| | | 7204 | សម្បទានរ៉ែ | 4.539,6 | 7.232,0 | 2.692,4 | 59,3% |
| | | 7205 | ការជួលដីទំនេរ | 6.005,4 | 9.166,4 | 3.161,0 | 52,6% |
| | 721 | | ផលមុនពីសហគ្រាសសាធារណៈ | 47.164,0 | 88.209,7 | 41.045,7 | 87,0% |
| | | 7212 | ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ | 47.164,0 | 88.200,0 | 41.036,0 | 87,0% |
| | | 7213 | ការបង់ប្រាក់រំលស់ | | 9,7 | 9,7 | !!! |
| **73** | | | **ផលមុនលើការលក់-ជួលទ្រព្យសម្បត្តិនិងសេវា** | **432.578,3** | **507.114,9** | **74.536,6** | **17,2%** |
| | 730 | | សហគ្រាសសាធារណៈ រដ្ឋបាល និង សេវាដំណើរការ ( រកចំណេញ) | 237.275,7 | 278.978,2 | 41.702,5 | 17,6% |
| | | 7301 | ផលមុនរបស់អាកាសចរស៊ីវិល | 51.730,0 | 58.405,0 | 6.675,0 | 12,9% |
| | | 7303 | ផលមុនពីសកម្មភាពទេសចរណ៍ | 118.413,2 | 150.070,9 | 31.657,7 | 26,7% |
| | | 7304 | ផលមុននៃសកម្មភាពវប្បធម៌ | 2.899,0 | 3.090,7 | 191,7 | 6,6% |
| | | 7305 | ផលមុនពីប្រៃសណីយ៍ និង ទូរគមនាគមន៍ | 60.522,5 | 64.824,0 | 4.301,5 | 7,1% |
| | | 7306 | ផលមុនពីវិទ្យុ និង ទូរទស្សន៍ | 997,1 | 832,2 | -164,9 | -16,5% |
| | | 7307 | ផលមុននៃសេវាផ្គត់ផ្គង់ទឹក | 1.518,0 | 20,4 | -1.497,6 | -98,7% |
| | | 7308 | ផលមុនផ្សេងៗទៀត | 1.195,9 | 1.735,0 | 539,1 | 45,1% |

# ការគ្រប់គ្រងឆ្នាំ ២០០៩

## តារាង "ក"

## ចំណូលថវិកាចរន្តរបស់រដ្ឋ

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ២០០៩/២០០៨ | |
|---|---|---|---|---|---|---|---|
| | | | | ២០០៨ | ២០០៩ | កើន (+) / ថយ (-) | ភាគរយ |
| | 731 | | រដ្ឋបាល និង សេវា ( មិនរកចំណេញ ) | 11.134,4 | 12.554,9 | 1.420,5 | 12,8% |
| | | 7311 | ការលក់សំភារៈបរិក្ខារ សំភារៈខូចខាត និង សំភារៈសិក្សា | 325,0 | 391,0 | 66,0 | 20,3% |
| | | 7312 | លក់ឯកសារ លតាប័ត្រ និង លិខិតបោះពុម្ពផ្សេងៗ | 10.132,0 | 11.626,2 | 1.494,2 | 14,7% |
| | | 7313 | ផលនៃការដឹកជញ្ជូនទំនិញ | 13,4 | 29,4 | 16,0 | 119,4% |
| | | 7315 | កំរៃនៃការថែទាំ | 664,0 | 358,3 | -305,7 | -46,0% |
| | | 7318 | ផលពីរដ្ឋបាល និង សេវាផ្សេងៗទៀត | | 150,0 | 150,0 | !!! |
| | 732 | | ផលពីការគ្រប់គ្រងរដ្ឋបាល | 164.433,8 | 198.198,1 | 33.764,3 | 20,5% |
| | | 7321 | អាករស្នាមទូត ( ចំណូលពីលិខិតឆ្លងដែន និង ទិដ្ឋាការ) | 132.000,0 | 161.660,0 | 29.660,0 | 22,5% |
| | | 7323 | ផលលើការបង្កើតសហគ្រាស | 700,0 | 831,4 | 131,4 | 18,8% |
| | | 7324 | ផលពីការបង់សិទ្ធប្រឡង | 270,0 | 412,0 | 142,0 | 52,6% |
| | | 7325 | ផលពីការលក់ស្លាកលេខ | 4.318,3 | 4.412,8 | 94,5 | 2,2% |
| | | 7326 | ចំណូលពីប្រដាប់ក្ដី | 388,0 | 634,5 | 246,5 | 63,5% |
| | | 7327 | សេវាសិរីយោដី និង សេវាសំណង់ | 2.876,0 | 3.717,0 | 841,0 | 29,2% |
| | | 7328 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និង ការគោរពបទដ្ឋាន | 23.881,5 | 26.530,4 | 2.648,9 | 11,1% |
| | 733 | | ការជួលទ្រព្យសម្បត្តិអចល័ត | 19.734,4 | 17.383,7 | -2.350,7 | -11,9% |
| | | 7331 | ការជួលសហគ្រាសសាធារណៈនៅថ្នាក់រដ្ឋបាលកណ្ដាល | 6.926,7 | 5.596,0 | -1.330,7 | -19,2% |
| | | 7332 | ការជួលសហគ្រាសសាធារណៈនៅខេត្តក្រុង ( មន្ទីរជំនាញ) | 6,4 | 2,4 | -4,0 | -62,5% |
| | | 7333 | ការជួលសំភារៈ និង មធ្យោបាយដឹកជញ្ជូន | 2,5 | 2,4 | -0,1 | -4,0% |
| | | 7334 | ការជួលអចលនវត្ថុ ( អសង្ហារិម) | 12.798,8 | 11.782,9 | -1.015,9 | -7,9% |
| **74** | | | **ផលពីការដាក់ពិន័យ និង ការដាក់ទណ្ឌកម្ម** | **750,0** | **2.269,0** | **1.519,0** | **202,5%** |
| | 741 | | ផលពីការដាក់ពិន័យ និង ការដាក់ទណ្ឌកម្ម | 750,0 | 2.269,0 | 1.519,0 | 202,5% |
| **76** | | | **ផលហិរញ្ញវត្ថុ** | **13.000,0** | **40.000,0** | **27.000,0** | **207,7%** |
| | 761 | | ការប្រាក់នៃការអោយខ្ចី | 13.000,0 | 40.000,0 | 27.000,0 | 207,7% |
| **77** | | | **ផលផ្សេងៗ និង ផលពិសេស** | **57.283,0** | **135.450,0** | **78.167,0** | **136,5%** |
| | 772 | | ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ | 40.000,0 | 130.000,0 | 90.000,0 | 225,0% |
| | 775 | | ផលពីការលក់អចលនវត្ថុ | 17.283,0 | 5.450,0 | -11.833,0 | -68,5% |
| | | | **ខ. សរុបចំណូលមូលធន (គ្រូ១+គ្រូ២)** | **321.400,0** | **383.000,0** | **61.600,0** | **19,2%** |
| | | | **ក្រុមទី១:ចំណូលពិត (ប្រភេទទី១+ប្រភេទទី២)** | **321.400,0** | **383.000,0** | **61.600,0** | **19,2%** |
| | | | **ប្រភេទទី១: ចំណូលពីប្រភពផ្ទាល់** | **100.000,0** | **48.000,0** | **-52.000,0** | **-52,0%** |
| **27** | | | **អចលកម្មហិរញ្ញវត្ថុ** | **100.000,0** | **48.000,0** | **-52.000,0** | **-52,0%** |
| | 271 | | ការអោយខ្ចី ( ការសងវិញនូវមូលធន ) | 100.000,0 | 48.000,0 | -52.000,0 | -52,0% |
| | | | **ប្រភេទទី២: ចំណូលពីប្រភពខាងក្រៅ** | **221.400,0** | **335.000,0** | **113.600,0** | **51,3%** |
| **13** | | | **ឧបត្ថម្ភធនវិនិយោគ** | **133.250,0** | **178.000,0** | **44.750,0** | **33,6%** |
| | 131 | | ឧបត្ថម្ភធនពីទ្វេភាគី | 46.125,0 | 86.000,0 | 39.875,0 | 86,4% |
| | | 1311 | ជប៉ុន | 46.125,0 | 30.000,0 | -16.125,0 | -35,0% |

# ការគ្រប់គ្រងឆ្នាំ ២០០៩
## តារាង "ក"
## ចំណូលថវិកាទូទៅរបស់រដ្ឋ

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ២០០៩/២០០៨ | |
|---|---|---|---|---|---|---|---|
| | | | | ២០០៨ | ២០០៩ | កើន (+) / ថយ (-) | ភាគរយ |
| | | 1318 | ផ្សេងៗ | | 56.000,0 | 56.000,0 | !!! |
| | 132 | | ឧបត្ថម្ភកធនពីពហុភាគី | 87.125,0 | 92.000,0 | 4.875,0 | 5,6% |
| | | 1321 | ធនាគារពិភពលោក | 61.500,0 | 60.000,0 | -1.500,0 | -2,4% |
| | | 1322 | ធនាគារអភិវឌ្ឍន៍អាស៊ី | | 32.000,0 | 32.000,0 | !!! |
| | | 1328 | ផ្សេងៗ | 25.625,0 | | -25.625,0 | -100,0% |
| **16** | | | **ការខ្ចី និង បំណុលប្រហាក់ប្រហែល** | **88.150,0** | **157.000,0** | **68.850,0** | **78,1%** |
| | 162 | | ការខ្ចីក្រៅប្រទេសពីពហុភាគី | 88.150,0 | 117.000,0 | 28.850,0 | 32,7% |
| | 163 | | ការខ្ចីក្រៅប្រទេសពីទ្វេភាគី | | 40.000,0 | 40.000,0 | !!! |
| **II. សរុបចំណូលវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស** | | | | **1.400.000,0** | **1.700.000,0** | **300.000,0** | **21,4%** |
| **ប្រភេទទី២: ចំណូលពីប្រភពខាងក្រៅ** | | | | **1.400.000,0** | **1.700.000,0** | **300.000,0** | **21,4%** |
| **13** | | | **ឧបត្ថម្ភកធនវិនិយោគ** | **750.000,0** | **900.000,0** | **150.000,0** | **20,0%** |
| | 131 | | ឧបត្ថម្ភកធនពីទ្វេភាគី | 750.000,0 | 900.000,0 | 150.000,0 | 20,0% |
| | | 1318 | ផ្សេងៗ | 750.000,0 | 900.000,0 | 150.000,0 | 20,0% |
| **16** | | | **ការខ្ចី និង បំណុលប្រហាក់ប្រហែល** | **650.000,0** | **800.000,0** | **150.000,0** | **23,1%** |
| | 162 | | ការខ្ចីក្រៅប្រទេសពីពហុភាគី | 650.000,0 | 800.000,0 | 150.000,0 | 23,1% |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ការគ្រប់គ្រងឆ្នាំ ២០០៩

## តារាង "ខ"

## ចំណាយថវិកាទូទៅរបស់រដ្ឋ

ឯកតា: លានរៀល

| ក្រសួង_ស្ថាប័ននានា | សរុបរួមចំណាយ | ចំណាយចរន្ត | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុបចំណាយចរន្ត | ប្រភេទទី ១ មធ្យោបាយសេវា | ប្រភេទទី ២ បន្ទុកហិរញ្ញវត្ថុ | ប្រភេទទី ៣ អន្តរាគមន៍សាធារណៈ | ប្រភេទទី ៤ ចំណាយផ្សេងៗ | ប្រភេទទី ៦ ចំណាយមិនបានគ្រោងទុក | សរុបចំណាយមូលធន | ប្រភេទទី ១ ការទូទាត់ប្រាក់កម្ចី | ប្រភេទទី ២ អចលកម្ម |
| **សរុបរួមចំណាយ** | **7.259.566,7** | **4.361.066,7** | **3.021.186,9** | **100.000,0** | **645.266,1** | **2.028,0** | **592.585,7** | **2.898.500,0** | **140.000,0** | **2.758.500,0** |
| **រដ្ឋបាលកណ្ដាល** | **6.200.444,0** | **3.301.944,0** | **2.015.723,2** | **100.000,0** | **592.313,1** | **1.322,0** | **592.585,7** | **2.898.500,0** | **140.000,0** | **2.758.500,0** |
| **មន្ទីរជំនាញខេត្ត-ក្រុង** | **1.059.122,7** | **1.059.122,7** | **1.005.463,7** | | **52.953,0** | **706,0** | | | | |
| **ក. វិស័យរដ្ឋបាលទូទៅ** | **610.089,7** | **610.089,7** | **471.433,3** | | **138.111,4** | **545,0** | | | | |
| រដ្ឋបាលកណ្ដាល | 572.504,0 | 572.504,0 | 433.850,6 | | 138.108,4 | 545,0 | | | | |
| មន្ទីរជំនាញខេត្ត-ក្រុង | 37.585,7 | 37.585,7 | 37.582,7 | | 3,0 | | | | | |
| ០១. ព្រះបរមរាជវាំង | 47.563,0 | 47.563,0 | 27.788,0 | | 19.730,0 | 45,0 | | | | |
| ០២. រដ្ឋសភា | 101.256,0 | 101.256,0 | 98.417,0 | | 2.839,0 | | | | | |
| ០៣. ព្រឹទ្ធសភា | 30.790,0 | 30.790,0 | 28.840,0 | | 1.900,0 | 50,0 | | | | |
| ០៤. ក្រុមប្រឹក្សាធម្មនុញ្ញ | 6.329,0 | 6.329,0 | 6.305,0 | | 20,0 | 4,0 | | | | |
| ០៥.១. ទីស្តីការគណៈរដ្ឋមន្ត្រី | 161.970,0 | 161.970,0 | 64.700,0 | | 97.170,0 | 100,0 | | | | |
| ០៥.២. រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | 3.177,0 | 3.177,0 | 3.177,0 | | | | | | | |
| ០៥.៤. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 5.769,0 | 5.769,0 | 5.746,0 | | | 23,0 | | | | |
| ០៧. ក្រសួងមហាផ្ទៃ-រដ្ឋបាលទូទៅ | 35.098,0 | 35.098,0 | 34.176,0 | | 922,0 | | | | | |
| ២. រដ្ឋបាលកណ្ដាល | 35.098,0 | 35.098,0 | 34.176,0 | | 922,0 | | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | | | | | | | | | | |
| ០៨. ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច | 12.232,4 | 12.232,4 | 12.212,4 | | | 20,0 | | | | |
| ១. រដ្ឋបាលកណ្ដាល | 7.104,0 | 7.104,0 | 7.084,0 | | | 20,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 5.128,4 | 5.128,4 | 5.128,4 | | | | | | | |
| ០៩. ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | 72.789,0 | 72.789,0 | 72.072,0 | | 700,0 | 17,0 | | | | |
| ១០. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | 74.758,6 | 74.758,6 | 59.698,6 | | 14.800,0 | 260,0 | | | | |
| ១. រដ្ឋបាលកណ្ដាល | 64.361,0 | 64.361,0 | 49.301,0 | | 14.800,0 | 260,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 10.397,6 | 10.397,6 | 10.397,6 | | | | | | | |
| ១៤. ក្រសួងផែនការ | 16.497,7 | 16.497,7 | 16.484,7 | | 13,0 | | | | | |
| ១. រដ្ឋបាលកណ្ដាល | 8.610,0 | 8.610,0 | 8.600,0 | | 10,0 | | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 7.887,7 | 7.887,7 | 7.884,7 | | 3,0 | | | | | |
| ២៦. ក្រសួងយុត្តិធម៌ | 26.926,0 | 26.926,0 | 26.910,0 | | 10,0 | 6,0 | | | | |
| ១. យុត្តិធម៌ | 7.232,0 | 7.232,0 | 7.226,0 | | | 6,0 | | | | |
| ២. តុលាការកំពូល | 2.388,0 | 2.388,0 | 2.378,0 | | 10,0 | | | | | |
| ៣. សាលាឧទ្ធរណ៍ | 2.165,0 | 2.165,0 | 2.165,0 | | | | | | | |
| ៤. ក្រុមប្រឹក្សាខែមង្គលចៅក្រម | 969,0 | 969,0 | 969,0 | | | | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 14.172,0 | 14.172,0 | 14.172,0 | | | | | | | |
| ៣០. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | 8.478,0 | 8.478,0 | 8.460,6 | | 1,4 | 16,0 | | | | |
| ៣១. អាជ្ញាធរសវនកម្មជាតិ | 6.456,0 | 6.456,0 | 6.446,0 | | 6,0 | 4,0 | | | | |
| **ខ. វិស័យការពារជាតិ និង សន្តិសុខ** | **895.894,0** | **895.894,0** | **882.807,0** | | **13.087,0** | | | | | |
| ០៦. ក្រសួងការពារជាតិ | 565.390,0 | 565.390,0 | 556.390,0 | | 9.000,0 | | | | | |
| ០៧.១. ក្រសួងមហាផ្ទៃ-សន្តិសុខសាធារណៈ | 330.504,0 | 330.504,0 | 326.417,0 | | 4.087,0 | | | | | |
| **គ. វិស័យសង្គមកិច្ច** | **1.599.566,3** | **1.599.566,3** | **1.304.430,6** | | **294.154,7** | **981,0** | | | | |
| រដ្ឋបាលកណ្ដាល | 696.973,3 | 696.973,3 | 441.572,6 | | 255.054,7 | 346,0 | | | | |
| មន្ទីរជំនាញខេត្ត-ក្រុង | 902.593,0 | 902.593,0 | 862.858,0 | | 39.100,0 | 635,0 | | | | |
| ១៦. ក្រសួងព័ត៌មាន | 34.938,0 | 34.938,0 | 34.899,0 | | 26,0 | 13,0 | | | | |
| ១. រដ្ឋបាលកណ្ដាល | 25.720,0 | 25.720,0 | 25.681,0 | | 26,0 | 13,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 9.218,0 | 9.218,0 | 9.218,0 | | | | | | | |

# ការគ្រប់គ្រងឆ្នាំ ២០០៩

## តារាង "ខ"

## ចំណាយថវិកាឆ្នាំទៅរបស់រដ្ឋ

ឯកតា: លានរៀល

| ក្រសួង_ស្ថាប័ននានា | សរុបរួម ចំណាយ | ចំណាយចរន្ត | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុប ចំណាយ ចរន្ត | ប្រភេទី ១ មធ្យោបាយ សេវា | ប្រភេទទី ២ បន្ទុក ហិរញ្ញវត្ថុ | ប្រភេទទី ៣ អន្តរាគមន៍ សាធារណៈ | ប្រភេទទី ៤ ចំណាយ ផ្សេងៗ | ប្រភេទទី ៦ ចំណាយមិន បានគ្រោងទុក | សរុប ចំណាយ មូលធន | ប្រភេទទី ១ ការវិនិយោគផ្ទាល់ ប្រាក់កម្ចី | ប្រភេទទី ២ អចលកម្ម |
| ១២. ក្រសួងសុខាភិបាល | 503.846,6 | 503.846,6 | 275.537,7 | | 228.023,9 | 285,0 | | | | |
| ១. រដ្ឋបាលកណ្ដាល | 342.819,6 | 342.819,6 | 124.637,7 | | 218.023,9 | 158,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 161.027,0 | 161.027,0 | 150.900,0 | | 10.000,0 | 127,0 | | | | |
| ១៦. ក្រសួងអប់រំ យុវជន និង កីឡា | 742.546,0 | 742.546,0 | 718.510,0 | | 23.467,0 | 569,0 | | | | |
| ១. អប់រំ | 177.729,0 | 177.729,0 | 168.147,0 | | 9.492,0 | 90,0 | | | | |
| ២. ឧត្តមសិក្សា | 33.163,0 | 33.163,0 | 32.717,0 | | 446,0 | | | | | |
| ៣. យុវជន និង កីឡា | 18.185,0 | 18.185,0 | 12.156,0 | | 6.029,0 | | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុងនានា | 513.469,0 | 513.469,0 | 505.490,0 | | 7.500,0 | 479,0 | | | | |
| ១៨. ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | 26.219,0 | 26.219,0 | 25.722,0 | | 487,0 | 10,0 | | | | |
| ១. រដ្ឋបាលកណ្ដាល | 16.100,0 | 16.100,0 | 15.603,0 | | 487,0 | 10,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 10.119,0 | 10.119,0 | 10.119,0 | | | | | | | |
| ១៩. ក្រសួងបរិស្ថាន | 19.540,0 | 19.540,0 | 19.342,0 | | 160,0 | 38,0 | | | | |
| ១. រដ្ឋបាលកណ្ដាល | 11.500,0 | 11.500,0 | 11.305,0 | | 160,0 | 35,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 8.040,0 | 8.040,0 | 8.037,0 | | | 3,0 | | | | |
| ២១. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | 181.477,0 | 181.477,0 | 154.980,0 | | 26.470,0 | 27,0 | | | | |
| ១. រដ្ឋបាលកណ្ដាល | 15.493,0 | 15.493,0 | 6.513,0 | | 8.970,0 | 10,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 165.984,0 | 165.984,0 | 148.467,0 | | 17.500,0 | 17,0 | | | | |
| ២៣. ក្រសួងធម្មការ និង សាសនា | 13.192,0 | 13.192,0 | 13.192,0 | | | | | | | |
| ១. រដ្ឋបាលកណ្ដាល | 5.568,0 | 5.568,0 | 5.568,0 | | | | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 7.624,0 | 7.624,0 | 7.624,0 | | | | | | | |
| ២៤. ក្រសួងកិច្ចការនារី | 25.595,0 | 25.595,0 | 19.596,0 | | 5.970,0 | 29,0 | | | | |
| ១. រដ្ឋបាលកណ្ដាល | 12.895,0 | 12.895,0 | 9.605,0 | | 3.270,0 | 20,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 12.700,0 | 12.700,0 | 9.991,0 | | 2.700,0 | 9,0 | | | | |
| ៣២. ក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ | 52.212,7 | 52.212,7 | 42.651,9 | | 9.550,8 | 10,0 | | | | |
| ១. រដ្ឋបាលកណ្ដាល | 37.800,7 | 37.800,7 | 29.639,9 | | 8.150,8 | 10,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 14.412,0 | 14.412,0 | 13.012,0 | | 1.400,0 | | | | | |
| **ឃ. វិស័យសេដ្ឋកិច្ច** | **360.931,0** | **360.931,0** | **332.516,0** | | **27.913,0** | **502,0** | | | | |
| រដ្ឋបាលកណ្ដាល | 241.987,0 | 241.987,0 | 227.493,0 | | 14.063,0 | 431,0 | | | | |
| មន្ទីរជំនាញខេត្ត-ក្រុង | 118.944,0 | 118.944,0 | 105.023,0 | | 13.850,0 | 71,0 | | | | |
| ០៥.៣. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | 11.778,0 | 11.778,0 | 11.508,0 | | 260,0 | 10,0 | | | | |
| ១៣. ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | 15.898,0 | 15.898,0 | 14.192,0 | | 1.681,0 | 25,0 | | | | |
| ១. រដ្ឋបាលកណ្ដាល | 6.981,0 | 6.981,0 | 6.825,0 | | 131,0 | 25,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 8.917,0 | 8.917,0 | 7.367,0 | | 1.550,0 | | | | | |
| ១៥. ក្រសួងពាណិជ្ជកម្ម | 38.008,0 | 38.008,0 | 34.723,0 | | 3.278,0 | 7,0 | | | | |
| ១. រដ្ឋបាលកណ្ដាល | 30.592,0 | 30.592,0 | 27.307,0 | | 3.278,0 | 7,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 7.416,0 | 7.416,0 | 7.416,0 | | | | | | | |
| ១៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | 76.987,0 | 76.987,0 | 62.938,0 | | 13.903,0 | 146,0 | | | | |
| ១. រដ្ឋបាលកណ្ដាល | 48.758,0 | 48.758,0 | 40.815,0 | | 7.803,0 | 140,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 28.229,0 | 28.229,0 | 22.123,0 | | 6.100,0 | 6,0 | | | | |
| ២០. ក្រសួងអភិវឌ្ឍន៍ជនបទ | 63.758,0 | 63.758,0 | 63.698,0 | | | 60,0 | | | | |
| ១. រដ្ឋបាលកណ្ដាល | 43.756,0 | 43.756,0 | 43.711,0 | | | 45,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 20.002,0 | 20.002,0 | 19.987,0 | | | 15,0 | | | | |

# ការគ្រប់គ្រងឆ្នាំ ២០០៩

## តារាង "ខ"

## ចំណាយថវិកានូនៅរបស់រដ្ឋ

ឯកតា:លានរៀល

| ក្រសួង_ស្ថាប័ននានា | សរុបរួមចំណាយ | ចំណាយចរន្ត | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុបចំណាយចរន្ត | ប្រភេទទី ១ មធ្យោបាយសេវា | ប្រភេទទី ២ បន្ទុកហិរញ្ញវត្ថុ | ប្រភេទទី ៣ អន្តរាគមន៍សាធារណៈ | ប្រភេទទី ៤ ចំណាយផ្សេងៗ | ប្រភេទទី ៦ ចំណាយមិនបានគ្រោងទុក | សរុបចំណាយមូលធន | ប្រភេទទី ១ ការទូទាត់ប្រាក់កម្ចី | ប្រភេទទី ២ អចលកម្ម |
| ២២. ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | 38.887,0 | 38.887,0 | 36.871,0 | | 1.991,0 | 25,0 | | | | |
| ១. រដ្ឋបាលកណ្តាល | 33.032,0 | 33.032,0 | 31.026,0 | | 1.991,0 | 15,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 5.855,0 | 5.855,0 | 5.845,0 | | | 10,0 | | | | |
| ២៥. ក្រសួងសាធារណការ និង ដឹកជញ្ជូន | 31.672,0 | 31.672,0 | 31.466,0 | | 100,0 | 106,0 | | | | |
| ១. រដ្ឋបាលកណ្តាល | 12.784,0 | 12.784,0 | 12.609,0 | | 100,0 | 75,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 18.888,0 | 18.888,0 | 18.857,0 | | | 31,0 | | | | |
| ២៧. ក្រសួងទេសចរណ៍ | 28.498,0 | 28.498,0 | 28.089,0 | | 400,0 | 9,0 | | | | |
| ១. រដ្ឋបាលកណ្តាល | 21.793,0 | 21.793,0 | 21.386,0 | | 400,0 | 7,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 6.705,0 | 6.705,0 | 6.703,0 | | | 2,0 | | | | |
| ២៨. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | 24.093,0 | 24.093,0 | 24.074,0 | | | 19,0 | | | | |
| ១. រដ្ឋបាលកណ្តាល | 13.757,0 | 13.757,0 | 13.740,0 | | | 17,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 10.336,0 | 10.336,0 | 10.334,0 | | | 2,0 | | | | |
| ២៩. ក្រសួងធនធានទឹក និង ឧតុនិយម | 31.352,0 | 31.352,0 | 24.957,0 | | 6.300,0 | 95,0 | | | | |
| ១. រដ្ឋបាលកណ្តាល | 18.756,0 | 18.756,0 | 18.566,0 | | 100,0 | 90,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 12.596,0 | 12.596,0 | 6.391,0 | | 6.200,0 | 5,0 | | | | |
| **៥៥. ចំណាយមិនទាន់បែងចែក** | **3.793.085,7** | **894.585,7** | **30.000,0** | **100.000,0** | **172.000,0** | | **592.585,7** | **2.898.500,0** | **140.000,0** | **2.758.500,0** |
| - បដិភាគចរន្ត | 30.000,0 | 30.000,0 | 30.000,0 | | | | | | | |
| - បន្ទុកហិរញ្ញវត្ថុ | 100.000,0 | 100.000,0 | | 100.000,0 | | | | | | |
| - ឧបត្ថម្ភខេត្ត ក្រុង និង ឃុំ សង្កាត់ | 172.000,0 | 172.000,0 | | | 172.000,0 | | | | | |
| - ចំណាយមិនបានគ្រោងទុក | 592.585,7 | 592.585,7 | | | | | 592.585,7 | | | |
| - ការទូទាត់ប្រាក់កម្ចី | 140.000,0 | | | | | | | 140.000,0 | 140.000,0 | |
| - តំរោងវិនិយោគ | 448.500,0 | | | | | | | 448.500,0 | | 448.500,0 |
| - បដិភាគវិនិយោគ | 185.000,0 | | | | | | | 185.000,0 | | 185.000,0 |
| - វិនិយោគដោយមូលនិធិទ្រទ្រង់ជីវិកា | 425.000,0 | | | | | | | 425.000,0 | | 425.000,0 |
| - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 1.700.000,0 | | | | | | | 1.700.000,0 | | 1.700.000,0 |

ROYAUME DU CAMBODGE · LE MINISTRE · PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ ២០០៩

## តារាង "គ១"

## វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា:ពាន់ដុល្លារអាមេរិក

| លេខ គំរោង | ឈ្មោះគំរោង | តំលៃ គំរោង | ប៉ាន់ស្មាន ២០០៨ | កម្រិតទុនវិនិយោគចែកតាមឆ្នាំ | | | |
|---|---|---|---|---|---|---|---|
| | | | | ២០០៩ | ២០១០ | ២០១១ | សរុប ៣ ឆ្នាំ |
| | **សរុបរួម** | **6.388.077** | **551.267** | **673.759** | **674.480** | **709.882** | **2.058.121** |
| **ក្រសួងសុខាភិបាល** | | **1.433.673** | **129.373** | **126.017** | **122.602** | **127.300** | **375.919** |
| 78 | ពង្រឹងសេវាសុខាភិបាលមូលដ្ឋាន | 580.523 | 41.400 | 42.500 | 38.000 | 38.000 | 118.500 |
| 82 | កម្មវិធីប្រយុទ្ធនឹងជម្ងឺរបេង | 105.000 | 6.500 | 6.327 | 5.519 | 5.700 | 17.546 |
| 83 | ការប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់ គ្រុនឈាម | 82.760 | 8.500 | 7.955 | 7.500 | 7.500 | 22.955 |
| 84 | កែទម្រង់ការចែកចាយឱសថស្ថាន និង សំភារៈ បរិក្ខារពេទ្យ | 348.757 | 52.567 | 52.324 | 54.656 | 58.621 | 165.601 |
| 86 | កម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ និង កាមរោគ | 88.396 | 8.107 | 5.703 | 5.213 | 5.798 | 16.714 |
| 87 | ការស្តារមន្ទីរពេទ្យជាតិ | 160.970 | 7.154 | 7.765 | 8.078 | 8.078 | 23.921 |
| 426 | ត្រួតពិនិត្យគ្រប់គ្រងចំណីអាហារ និង ថ្នាំសង្កូវ | 8.699 | 1.320 | 322 | 326 | 326 | 974 |
| 701 | អភិវឌ្ឍន៍ឱសថបុរាណ | 8.318 | 130 | 147 | 184 | 184 | 515 |
| 962 | គំរោងគ្រប់គ្រងជម្ងឺកុមារ (IMCI) | 6.904 | 1.300 | 1.300 | 1.300 | 1.300 | 3.900 |
| 1024 | កម្មវិធីត្រួតពិនិត្យ និង អន្តរាគមន៍សុខភាពសាធារណៈ | 25.059 | 444 | 1.674 | 1.826 | 1.793 | 5.293 |
| 1096 | ការផ្តល់សុខភាពបឋមនៅខេត្តកំពង់ចាម | 5.213 | 560 | | | | |
| 1097 | ការផ្តល់សេវាកម្មសុខភាពបឋមនៅខេត្តសៀមរាប និង ឧត្តរមានជ័យ | 5.725 | 596 | | | | |
| 1100 | គំរោងត្រួតពិនិត្យរបេង ជំហានទី២ | 592 | 118 | | | | |
| 1102 | គំរោងអភិវឌ្ឍន៍ធនធានមនុស្សផ្នែកសុខាភិបាល | 1.291 | 191 | | | | |
| 1316 | អភិវឌ្ឍន៍ធនធាន និង សេវាសុខភាពផ្លូវចិត្ត | 5.466 | 486 | | | | |
| **ក្រសួងអប់រំ យុវជន និងកីឡា** | | **461.901** | **62.488** | **63.084** | **62.027** | **43.183** | **168.294** |
| 719 | កម្មវិធីអភិវឌ្ឍន៍សំភារៈរូបវន្ត | 168.000 | 17.860 | 16.000 | 17.000 | 13.234 | 46.234 |
| 876 | ការអប់រំមូលដ្ឋាន និងបណ្តុះបណ្តាលគ្រូបង្រៀននៅខេត្តសៀមរាប ឧត្តរមានជ័យ និង កំពង់ចាម | 16.171 | 2.472 | 2.955 | 2.955 | 8.955 | 14.865 |
| 1063 | គំរោងទ្រទ្រង់វិស័យអប់រំនៅកម្ពុជា | 39.000 | 7.499 | 7.172 | 9.695 | 8.000 | 24.867 |
| 1067 | គំរោងកែលម្អការចូលរៀននៅបឋមសិក្សាក្នុងឃុំជួបការលំបាក | 1.870 | 353 | | | | |
| 1071 | កម្មវិធីពង្រីកការអប់រំមូលដ្ឋានជំហានទី ២ | 25.700 | 4.450 | 4.000 | 8.450 | | 12.450 |
| 1073 | ថវិកាគាំទ្រកំណែទម្រង់ការអប់រំមូលដ្ឋានដល់សិស្សក្រីក្រ | 21.000 | 3.350 | 4.350 | 6.350 | | 10.700 |
| 1074 | កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំលើកទី២ | 25.000 | 5.500 | 8.000 | | | 8.000 |
| 1075 | គំរោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សា | 33.580 | 7.316 | 7.316 | | | 7.316 |
| 1127 | ទំនាក់ទំនងការផ្លាស់ប្តូរឥរិយាបថសុខភាព | 6.176 | 1.521 | 1.500 | | | 1.500 |
| 1144 | ការអប់រំប្រកបដោយសមធម៌នៅបឋម និង មធ្យមសិក្សា | 32.125 | 2.500 | | | | |
| 1145 | ពង្រឹងការរៀបចំផែនការ និង គ្រប់គ្រង | 9.533 | 834 | | | | |
| [illegible] | កម្មវិធីផ្តល់អាហារសំរន់ពេលព្រឹក និង របបអង្ករយកទៅផ្ទះ | 63.739 | 8.833 | 9.833 | 12.833 | | 22.666 |
| [illegible] | [illegible]សង់ផ្ទះ[illegible]ម្រាប់គ្រូមធ្យមសិក្សា | 10.726 | | 500 | 2.000 | 8.000 | 10.500 |

ប្រភពៈ [illegible]ក្រសួង-ស្ថាប័ននានា។ ប្រភពព័ត៌មាន:ទិន្នន័យនៃកម្មវិធីវិនិយោគសាធារណៈក្រសួងផែនការ

 ksl

# ការគ្រប់គ្រងឆ្នាំ ២០០៩

## តារាង "គ១"

## វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា:ពាន់ដុល្លារអាមេរិក

| លេខ គំរោង | ឈ្មោះគំរោង | តំលៃ គំរោង | ប៉ាន់ស្មាន ២០០៨ | កម្រិតទុនវិនិយោគចែកតាមឆ្នាំ | | | |
|---|---|---|---|---|---|---|---|
| | | | | ២០០៩ | ២០១០ | ២០១១ | សរុប ៣ ឆ្នាំ |
| 1342 | សាងសង់អន្តេវាសិកដ្ឋានសម្រាប់សិស្សមធ្យមសិក្សា | 6.824 | | 500 | 2.000 | 4.300 | 6.800 |
| 1416 | កែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា | 1.475 | | 575 | 474 | 426 | 1.475 |
| 1418 | អភិវឌ្ឍន៍កម្មវិធីបង្រៀនគណិតវិទ្យានៅកម្ពុជា | 580 | | 213 | 185 | 182 | 580 |
| 1419 | រៀបចំទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រ | 296 | | 155 | 70 | 71 | 296 |
| 1420 | កែលម្អទំនាក់ទំនង និង កិច្ចសហប្រតិបត្តិការស្តីពីការអប់រំ | 106 | | 15 | 15 | 15 | 45 |
| **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | **343.710** | **13.038** | **51.185** | **74.116** | **111.797** | **237.098** |
| 1147 | កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម | 27.500 | 740 | 740 | | | 740 |
| 1148 | គំរោងអភិវឌ្ឍន៍វិស័យកសិកម្ម | 5.880 | 2.282 | 2.283 | | | 2.283 |
| 1152 | គំរោងស្តារឡើងវិញលើវិស័យសេដ្ឋកិច្ច-សង្គមកិច្ច នៅខេត្តភាគពាយ័ព្យ (អេកូសួន) | 31.879 | 5.000 | 16.882 | 14.882 | | 31.764 |
| 1158 | គំរោងស្រាវជ្រាវវារីវប្បកម្ម | 86 | 17 | 17 | 17 | 17 | 51 |
| 1159 | គំរោងចិញ្ចឹមសត្វ កម្ពុជា-អឺរ៉ុប | 6.176 | 600 | 1.735 | 1.735 | 236 | 3.706 |
| 1162 | លើកកម្ពស់រុក្ខកម្មតាមសហគមន៍ | 2.005 | 400 | 401 | 401 | 401 | 1.203 |
| 1202 | គំរោងកាត់បន្ថយភាពក្រីក្រនៅខេត្តស្វាយរៀង និង ព្រៃវែង | 17.500 | 3.000 | 4.200 | 3.005 | 4.200 | 11.405 |
| 1206 | គំរោងអភិវឌ្ឍន៍ក្នុងខេត្តបាត់ដំបង | 3.268 | 999 | | | | |
| 134 | ពង្រីកការដាំកៅស៊ូ | 2.776 | | 532 | 1.609 | 635 | 2.776 |
| 144 | ស្រាវជ្រាវកសិផល និង ផលិតផលគ្រាប់ពូជ | 9.200 | | 3.000 | 2.000 | 4.100 | 9.100 |
| 151 | សាងសង់ការិយាល័យតាមដានការនេសាទ | 1.250 | | 200 | 200 | 800 | 1.200 |
| 152 | ស្តារឡើងវិញវិទ្យាស្ថានសិក្សាពីសមុទ្រ | 8.000 | | 500 | 1.500 | 1.500 | 3.500 |
| 157 | សំណើសុំវ៉ាក់សាំង ថ្នាំ និង ឧបករណ៍ | 221 | | 11 | 100 | 110 | 221 |
| 161 | អភិវឌ្ឍន៍មជ្ឈមណ្ឌលចិញ្ចឹមគោ ក្របី | 6.165 | | 200 | 1.265 | 4.700 | 6.165 |
| 170 | ការរៀបចំ និង គ្រប់គ្រងសត្វព្រៃ | 3.420 | | 100 | 12 | 2.500 | 2.612 |
| 174 | សាងសង់អាគារបំរើឱ្យវិស័យកសិកម្ម | 2.500 | | 1.000 | 1.000 | 500 | 2.500 |
| 175 | លើកកម្ពស់ស្ថានីយស្រាវជ្រាវ | 1.390 | | 577 | 467 | 242 | 1.286 |
| 183 | គ្រប់គ្រងព្រៃបំរុងទុកសម្រាប់សត្វស្លាប | 2.000 | | 50 | 100 | 100 | 250 |
| 216 | ការកែលម្អថ្មីនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 4.500 | | 1.000 | 1.500 | 2.000 | 4.500 |
| 229 | សិក្សាសត្វស្លាបទឹក | 1.000 | | 100 | 120 | 30 | 250 |
| 302 | សាងសង់ជួសជុលអាគារមន្ទីរកសិកម្មខេត្តក្រុង | 2.112 | | 100 | 300 | 400 | 800 |
| 328 | គំរោងគ្រប់គ្រងព្រៃព្រែកទឹកសាប | 14.600 | | 250 | 4.000 | 5.000 | 9.250 |
| 329 | ស្ថាបនាមូលដ្ឋានអភិរក្សសត្វព្រៃនៅឧទ្យានភ្នំតាម៉ៅ | 426 | | 100 | 59 | 59 | 218 |
| [illegible] | [illegible]ប្រាបបទល្មើសសត្វព្រៃ | 257 | | 20 | 73 | 73 | 166 |
| [illegible] | [illegible]ស្ថានីយគោកគ្រប់ និងព្រៃផ្តៅ | 194 | | 72 | 109 | | 181 |

# ការគ្រប់គ្រងឆ្នាំ ២០០៩

## តារាង "គ១"

## វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

ឯកតា:ពាន់ដុល្លារអាមេរិក

| លេខ គំរោង | ឈ្មោះគំរោង | តំលៃ គំរោង | ប៉ាន់ស្មាន ២០០៨ | កម្រិតមុនវិនិយោគចែកតាមឆ្នាំ | | | |
|---|---|---|---|---|---|---|---|
| | | | | ២០០៩ | ២០១០ | ២០១១ | សរុប ៣ ឆ្នាំ |
| 514 | អភិរក្សការគ្រប់គ្រង និង អភិវឌ្ឍន៍ជលផល | 13.561 | | 2.000 | 3.000 | 4.000 | 9.000 |
| 520 | ជួសជុលសាលាកសិកម្មកំពង់ចាម | 10.414 | | 200 | 2.000 | 8.200 | 10.400 |
| 521 | ស្ថានីយបង្កាត់ពូជគោដោយសិប្បនិម្មិត | 91 | | 33 | 58 | | 91 |
| 523 | បង្កើតស្ថានីយស្រាវជ្រាវវារីវប្បកម្មសមុទ្រ | 8.000 | | 500 | 2.500 | 4.500 | 7.500 |
| 524 | ស្ថានីយស្រាវជ្រាវវារីវប្បកម្មទឹកសាប ទឹកឆា | 10.535 | | 500 | 500 | 500 | 1.500 |
| 617 | ការស្រាវជ្រាវលើការគ្រប់គ្រងធញ្ញជាតិ | 417 | | 89 | 115 | 213 | 417 |
| 619 | ជួសជុលមជ្ឈមណ្ឌលបច្ចេកទេសកសិកម្មទួលសំរោង | 16.500 | | 200 | 3.200 | 13.050 | 16.450 |
| 630 | ផលិតវ៉ាក់សាំង | 400 | | 222 | 39 | 39 | 300 |
| 686 | ការបង្ហាញលើក្សេត្រសាស្ត្របសុសត្វ និង ការចិញ្ចឹមត្រី | 1.900 | | 100 | 1.400 | 400 | 1.900 |
| 694 | វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កសិ-ឧស្សាហកម្ម | 16.700 | | 939 | 4.763 | 10.709 | 16.411 |
| 750 | អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអប់រំនៅសកលវិទ្យាល័យភូមិន្ទកសិកម្ម | 13.100 | | 500 | 500 | 12.000 | 13.000 |
| 751 | ផ្សព្វផ្សាយបច្ចេកវិជ្ជាគ្រឿងយន្តកសិកម្ម | 4.000 | | 340 | 284 | 3.200 | 3.824 |
| 771 | ការគ្រប់គ្រងព្រៃឈើអាងទន្លេមេគង្គ | 1.610 | | 200 | 200 | 200 | 600 |
| 810 | ផលិតផលកសិកម្ម និង កសិ-ពាណិជ្ជកម្ម | 4.500 | | 90 | 1.050 | 3.000 | 4.140 |
| 816 | ពង្រឹងទីផ្សារបសុសត្វ | 300 | | 80 | 90 | 130 | 300 |
| 825 | ការអភិរក្សទប់ស្កាត់ការខ្សោះជីវជាតិដី | 827 | | 428 | 267 | 132 | 827 |
| 906 | បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវសាកវប្បកម្មកប់ស្រូវ | 17.000 | | 4.000 | 5.400 | 7.500 | 16.900 |
| 907 | ការបង្រ្កាបការរុករានទន្ទ្រានព្រៃឈើ | 10.000 | | 200 | 2.300 | 2.300 | 4.800 |
| 988 | គំរោងដាំឈើ និង ដាំឈើឡើងវិញចំនួន ២.០០០ ហិកតា | 1.474 | | 200 | 200 | 200 | 600 |
| 992 | សាងសង់ស្ថានីយស្រាវជ្រាវគ្រាប់ពូជ និង ដាំដើមឈើ | 100 | | 25 | 25 | 50 | 100 |
| 1029 | បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និង ផ្សព្វផ្សាយកសិកម្ម អូសណ្តាស់ | 402 | | 144 | 137 | 121 | 402 |
| 1034 | អភិវឌ្ឍន៍គុណភាពផ្នែកអនុវត្ត និងលើកកម្ពស់បទដ្ឋានពិសោធន៍ សកលវិទ្យាល័យភូមិន្ទកសិកម្ម | 543 | | 182 | 182 | 179 | 543 |
| 1036 | អភិវឌ្ឍន៍ការចិញ្ចឹមសត្វ | 6.489 | | 639 | 2.500 | 3.350 | 6.489 |
| 1037 | ការគ្រប់គ្រងធនធានទឹកចំរុះសម្រាប់ប្រពលវប្បកម្មដំណាំ និង ការផ្លាស់ប្តូរ ប្រព័ន្ធកសិកម្មនៅកំពង់ឆ្នាំង | 5.081 | | 1.000 | 1.500 | 2.800 | 5.300 |
| 1039 | គំរោងគំរូសម្រាប់ការគ្រប់គ្រងទីជំរាលចំរុះក្នុងអាងទន្លេសេកុង និង ស្រែពក ប្រទេសកម្ពុជា | 1.194 | | 761 | 280 | 153 | 1.194 |
សមានគុណជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក.គ្រឿងឥស្សរិយយសសុវត្ថារា ថ្នាក់ មហាសេនា ចំពោះ :

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១- | ឧត្តមសេនីយ៍ទោ | ចាប | ភក្តី | ២- | ឧត្តមសេនីយ៍ទោ | យូ | សិរីវុឌ្ឍ |

ខ.គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ :

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១- | វរសេនីយ៍ឯក | ម៉ៅ | ពៅ | ២- | វរសេនីយ៍ឯក | ឆុំ | សារ៉ាវុធ |

គ.គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១- | វរសេនីយ៍ឯក | ផូ | គ្រួយ | ៣- | វរសេនីយ៍ទោ | អ៊ុំ | សារុន |
| ២- | វរសេនីយ៍ទោ | ជា | សុខ | | | | |

ឃ.គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១- | វរសេនីយ៍ទោ | ស៊ុំ | សំណាង | ៧- | វរសេនីយ៍ទោ | ឆេព | ឈឿន |
| ២- | វរសេនីយ៍ទោ | ធី | សារ៉ុម | ៨- | វរសេនីយ៍ទោ | ប៊ូ | គេន |
| ៣- | វរសេនីយ៍ទោ | ជា | សុធី | ៩- | វរសេនីយ៍ទោ | សូ | ឡុម |
| ៤- | វរសេនីយ៍ទោ | ថុល | សុវណ្ណ | ១០- | វរសេនីយ៍ត្រី | ឆិត្យ | ឈន |
| ៥- | វរសេនីយ៍ទោ | ពៅ | សារុន | ១១- | វរសេនីយ៍ត្រី | ឃឹម | យឿន |
| ៦- | វរសេនីយ៍ទោ | ប៉ែន | សារឿត | | | | |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៩៧. ០៩១២. ១៤៤១

លេខៈ ១៣៣៥ ច.ល

ដើម្បីចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៨

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រីធិបាល

ស៊ុន ចិនគេន

# ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១៤៧២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

ឯកឧត្តម លី គឹមឡុង

ព្រះហស្តលេខា និងព្រះរាជលញ្ចករ

នរោត្តម សីហមុនី

៣រ៧.០៩១២.១៤៤២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨

លេខ: ៣៣៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៨

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១៤២៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគុណជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក.គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :-

១-ឧត្តមសេនីយ៍ត្រី ខួត សំខាន់ អត្តលេខ ០០២៥៣៧

២-ឧត្តមសេនីយ៍ត្រី លី សុវិរិទ្ធ អត្តលេខ ០០១១៥៤

៣-ឧត្តមសេនីយ៍ត្រី ខាំ ស៊ុក អត្តលេខ ០០០៨៧៧

៤-ឧត្តមសេនីយ៍ត្រី ជ័យ សែន អត្តលេខ ០០០៥០៧

ខ.គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :-

វរសេនីយ៍ត្រី មុំ សំអឿន អត្តលេខ ០២៨១២៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩ល.០៩១២.១៤៤៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨

លេខ: ១៣៦៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០៨
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១៤២៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ឧត្តមសេនីយ៍ទោ ង្វៀន ជុងធូ (NGUYEN TRUNG THU)

នូវ

## គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល.០៩១២.១៤៤៤

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨*

លេខ:១៣១៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៨

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១៤២៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១- ឯកឧត្តម ជឹម លាង
២- ឯកឧត្តម គង់ ឈឹម
៣- លោក ហៃ ចូនលី
៤- លោក គួប សារ៉ុម
៥- លោក ធុច ថាត

ខ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១- ឯកឧត្តម ស៊ិន សម្ពល្ល

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

១- ឯកឧត្តម ហ្វូង សេងហួរ
២- លោក បាន ចណ្ណី
៣- លោក មាស សុខុម
៤- លោក អុំ ប៊ុនលី
៥- លោក ជឹម សេងហួង

ឃ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ចំពោះ :

១- លោក ម៉ុង យ៉េន
២- លោក បាន ប៊ុនធឿន
៣- លោក ជីង ហាត់
៤- លោក ប៊ុន អេង
៥- លោកឧកញ៉ា ឈន ផាធី
៦- លោក ធួច នៃ
៧- លោក ហួត គឹមហ៊ាន
៨- លោក អ៊ុម ឌិបុល
៩- លោក ឡឹ ចណ្ណា
១០- លោក ហ៊ុន ស៊ាងហេង
១១- លោក ម៉េង សួន
១២- លោក ប៊ិ ប៊ុន្ណា
១៣- លោក ហ៊ី ណារ៉េន
១៤- លោក តែង ចណ្ណះ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ង - គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ សេនា ចំពោះ :

១- លោក ប៉ែន ម៉ារឌី

២- លោក ខាន់ សុវណ្ណ

៣- លោក នួន ស៊ីវ៉ាញឿន

៤- លោក ឆង គុយច្រា

៥- លោក ហេង គុសលបុត្រ

ច- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ សេនា ចំពោះ :

១- លោក ឈុន ប៊ុនណារិទ្ធ

២- លោក អោគ សាមីន

៣- លោក គីម តៃ

៤- លោក ទួច ឡេង

៥- លោក យូ ស្រ៊ុន

៦- លោក ស៊ាន សុគុណ

៧- លោក ឃី តាំងឡាយ

៨- លោក អោគ សាឌុង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ពរ.ល.០៩១២.១៤៤៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៨

លេខ : ០៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមករា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

នស/រកត/១២០៨/១៤២៦

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១- ឯកឧត្តម ស្លូត សំបូរ

ខ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១- ឯកឧត្តម ហ៊ី បាទី

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

| | | | | | |
|---|---|---|---|---|---|
| ១- | ឯកឧត្តម | លី ស៊ីវណ្ណា | ៦- | លោក | ទីវ គីមពិសិដ្ឋ |
| ២- | ឯកឧត្តម | អៀង ម៉េងស៊ុន | ៧- | លោក | ជៀម ថុល |
| ៣- | ឯកឧត្តម | អាន សំអុល | ៨- | លោក | ម៉ម រិទ្ធី |
| ៤- | លោក | តែន សម្បត្តិ | ៩- | លោកស្រី | គឹម សែន |
| ៥- | លោក | ចម បូរិទ្ធ | | | |

ឃ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | ញ៉ាំ សុខានី | ៥- | លោក | គុយ ប៊ុនធន |
| ២- | លោក | គន់ ជួន | ៦- | លោក | ឈិត សុគ |
| ៣- | លោក | ណែម ធីម | ៧- | លោក | សូ សីហា |
| ៤- | លោក | ជី ទិចិត្រ | | | |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៩១២.១៤៤៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៨

លេខ: ០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែមករា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១៤២៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជាកិច្ចបច្ឆាមរណៈជូនសពលោក ម៉ិន ហោ ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៦ ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៦ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

៣រល.០៩១២.១៤៤៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨*

លេខ : ០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ [illegible] ឆ្នាំ២០០៩
រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋាភិបាល

[illegible] ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១៤៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

**ប្រោសព្រះរាជទាន**

ជាកិច្ចបច្ឆាមរណៈ

ចំពោះ

សពលោក **ប៊ុន ហោ**

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រ.ល.០៩១៧.១៤៤៩

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨*

លេខៈ ០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១៤២៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

# ត្រាស់បង្គាប់

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើត "**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**" ដែលមានឈ្មោះជាអក្សរកាត់ថា "**គ.ជ.អ.ប**" ដើម្បីសម្របសម្រួលដឹកនាំការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

## ជំពូកទី ២
## សមាសភាព និង បេសកកម្ម

**មាត្រា ២.-**

គ.ជ.អ.ប មានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- | រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២- | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៣- | រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាអនុប្រធាន |
| ៤- | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាសមាជិក |
| ៥- | រដ្ឋមន្ត្រីក្រសួងផែនការ | ជាសមាជិក |
| ៦- | រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៧- | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | ជាសមាជិក |
| ៨- | រដ្ឋមន្ត្រីក្រសួងសុខាភិបាល | ជាសមាជិក |
| ៩- | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ១០- | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | ជាសមាជិក |
| ១១- | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ជាសមាជិក |
| ១២- | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ជាសមាជិក |
| ១៣- | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ០១រូប | ជាសមាជិក |
| ១៤- | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប | ជាសមាជិក |
| ១៥- | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ០១រូប | ជាសមាជិក |
| ១៦- | ប្រធានលេខាធិការដ្ឋាននៃ គ.ជ.អ.ប | ជាសមាជិកអចិន្ត្រៃយ៍ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង

ក្រៅពីសមាជិកខាងលើនេះ គ.ជ.អ.ប អាចស្នើបន្ថែមសមាជិកជារដ្ឋមន្ត្រី ឬប្រធានស្ថាប័ននៃក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល តាមការចាំបាច់។

សមាជិកម្នាក់ៗត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន គ.ជ.អ.ប។ ក្នុងករណីមិនអាចចូលរួមប្រជុំបាន សមាជិកនោះអាចតែងតាំងតំណាងមួយរូប ដែលជាសមាជិករាជរដ្ឋាភិបាល ដើម្បីជំនួសខ្លួននៅក្នុងការចូលរួមកិច្ចប្រជុំ ដោយធ្វើប្រតិភូកម្មអំណាចឱ្យតំណាងរូបនោះមានសិទ្ធិសម្រេចជំនួសខ្លួន។

គ.ជ.អ.ប អាចអញ្ជើញរដ្ឋមន្ត្រីក្រសួង ស្ថាប័ន ឬអាជ្ញាធរ ឬអ្នកពាក់ព័ន្ធផ្សេងៗទៀត ឱ្យចូលរួមប្រជុំ ការពិភាក្សា ឬសហការការងារតាមការចាំបាច់។

**មាត្រា ៣.-**

គ.ជ.អ.ប មានបេសកកម្មសំខាន់ៗដូចខាងក្រោម ÷

- តាក់តែង និងអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

- ផ្អែកលើកម្មវិធីជាតិ គ.ជ.អ.ប ត្រូវរៀបចំផែនការសកម្មភាព និងគម្រោងថវិកាប្រចាំឆ្នាំ។

- ការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាពកម្មវិធីជាតិ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត ឱ្យបានសមស្រប។

- ពិគ្រោះ ពិភាក្សា សម្របសម្រួលជាមួយគ្រប់ក្រសួង ស្ថាប័នក្នុងការពិនិត្យមើលឡើងវិញនូវការទទួលខុសត្រូវ និងមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីកំណត់មុខងារ ការទទួលខុសត្រូវ សិទ្ធិអំណាច និងគណនេយ្យភាពសម្រាប់ផ្ទេរដល់ក្រុមប្រឹក្សានានានៅថ្នាក់ក្រោមជាតិ ដោយរួមជាមួយនឹង ÷

+ ការផ្ទេរធនធាន រួមមាន ចំណូល ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិ និងសមត្ថភាព ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារនីមួយៗ។

+ ការផ្តល់លទ្ធភាព និងអំណាច ដើម្បីទទួលបានធនធានចាំបាច់រួមមានចំណូល ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិ និងសមត្ថភាពសម្រាប់គ្រប់គ្រង និងអនុវត្តមុខងារនីមួយៗនោះ។

+ ការផ្តល់អំណាច និងភារកិច្ច ដើម្បីគ្រប់គ្រង និងអនុវត្តរាល់មុខងាររបស់ខ្លួនតាមគោលការណ៍ស្វ័យភាពមូលដ្ឋាន និងគណនេយ្យភាពនៅមូលដ្ឋានក្នុងកម្រិតជាអតិបរមា។



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

- ក្នុងពេលរង់ចាំការផ្ទេរមុខងារ និងការទទួលខុសត្រូវដល់ក្រុមប្រឹក្សានានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ គ.ជ.អ.ប ត្រូវកំណត់បែបបទ និងនីតិវិធីសម្រាប់ធ្វើសមាហរណកម្មនូវផែនការអភិវឌ្ឍន៍ និងថវិកានៃក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិទៅក្នុងផែនការអភិវឌ្ឍន៍ និងថវិការបស់ក្រុមប្រឹក្សាតាមប្រភេទនីមួយៗ។

- អាចផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នណាមួយនៃរាជរដ្ឋាភិបាល អំពីការតាក់តែង ឬការធ្វើវិសោធនកម្មច្បាប់ ឬលិខិតបទដ្ឋាននានា ដើម្បីឱ្យស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

- ពិគ្រោះពិភាក្សា សម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានាតាមការចាំបាច់ ដើម្បីរៀបចំឱ្យមានរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងការរៀបចំបែបបទ នីតិវិធីនៃការរៀបចំ ការអនុម័ត និងការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំប្រភពចំណូលរួមមាន ចំណូលពីថ្នាក់ជាតិ និងចំណូលនៅមូលដ្ឋាន ការផ្ទេរឧបត្ថម្ភថវិកា រួមមានមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ និងមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌពីថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្ទេរទ្រព្យសម្បត្តិរដ្ឋ ការចាត់ចែង ការគ្រប់គ្រង ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដែលប្រគល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិរកបានដោយខ្លួនឯង ដោយមានផែនការជាជំហានៗ មានសនិទានភាព មានការសម្របសម្រួល មានការពិគ្រោះយោបល់ មានតម្លាភាព និងមានគណនេយ្យភាព។

- សហការជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដើម្បីកំណត់គោលនយោបាយ យុទ្ធសាស្ត្រសម្រាប់ការពិនិត្យ និងការកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិក ស្របពេលជាមួយនឹងការផ្ទេរមុខងារ និងការទទួលខុសត្រូវ ក្នុងគោលបំណងបង្កើតឱ្យមានក្របខ័ណ្ឌបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទៅតាមរបៀបដែលមានផែនការ មានកម្មវិធី មានសនិទានភាព មានការពិគ្រោះយោបល់ និងមានតម្លាភាព។

- កំណត់អំពីប្រភេទបុគ្គលិកសម្រាប់ប្រភេទក្រុមប្រឹក្សានីមួយៗ និងកំណត់អំពីរបៀប និងគោលនយោបាយក្នុងការកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិក ដោយធានាមិនឱ្យមានការបង្កើនចំនួនបុគ្គលិកសាធារណៈ។

- សហការជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធតាមការចាំបាច់ ដើម្បីរៀបចំសេចក្តីព្រាងលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

- ត្រូវធានាឱ្យមានការសម្របសម្រួល និងពិគ្រោះយោបល់អំពីគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់នានាដែលអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធនានាដើម្បីឱ្យមានសង្គតិភាពជាមួយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងកម្មវិធីជាតិ។

- សិក្សាស្រាវជ្រាវ និងកំណត់ឡើងវិញនូវព្រំប្រទល់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិតាមការចាំបាច់។

- សិក្សាស្រាវជ្រាវអំពីកំណើនទីក្រុង និងនគរូបនីយកម្ម សម្រាប់ជាមូលដ្ឋានបង្កើតនូវគោលនយោបាយ រចនាសម្ព័ន្ធ និងយុទ្ធសាស្ត្រគ្រប់គ្រងទីក្រុងឱ្យបានសមស្រប។

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ សម្រាប់កសាងសមត្ថភាពក្រុមប្រឹក្សា និងរដ្ឋបាលរបស់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ។

- សហការសិក្សាស្រាវជ្រាវ និងផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាល ក្នុងការបង្កើតនូវមូលនិធិសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដ៏សមស្របមួយ ដើម្បីប្រមូលផ្តុំប្រភពធនធានពីដៃគូអភិវឌ្ឍន៍នានាសម្រាប់តម្រូវការផ្នែកបុគ្គលិក និងកិច្ចសហប្រតិបត្តិការការអភិវឌ្ឍន៍ ការគាំទ្រផ្នែកបច្ចេកទេស និងតម្រូវការចាំបាច់នានានៅថ្នាក់ក្រោមជាតិ ព្រមទាំងការផ្តល់ជំនួយបច្ចេកទេសដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា។

- ស្រាវជ្រាវ ពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាលអំពីទម្រង់សម្រាប់កៀរគរ និងប្រើប្រាស់ធនធាននៅក្នុង និងក្រៅប្រទេស សម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

- ស្រាវជ្រាវ និងរៀបចំនូវកិច្ចព្រមព្រៀងមួយរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍សម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីធានាឱ្យដៃគូអភិវឌ្ឍន៍ទាំងអស់ជាភាគីនៃកិច្ចព្រមព្រៀងនេះ ដែលជាការធានានូវការតម្រឹម និងសុខដុមនីយកម្មក្នុងការប្រើប្រាស់ជំនួយ។

- បង្កើតនូវវេទិកាដ៏សមស្របមួយរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាសម្រាប់សម្របសម្រួលកិច្ចសហប្រតិបត្តិការ និងការគាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

6/12

- ធានាឱ្យមានការផ្ទេរសិទ្ធិ និងការទទួលខុសត្រូវពីរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ បច្ចុប្បន្នទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលបានបង្កើត ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

- ធ្វើសេចក្តីរាយការណ៍ជូនរាជរដ្ឋាភិបាលរៀងរាល់មួយឆ្នាំម្តង អំពីការអនុវត្តច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

- បំពេញការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីរាជរដ្ឋាភិបាល។

## ជំពូកទី ៣
## អំពីការទទួលខុសត្រូវ និងសិទ្ធិអំណាច

**មាត្រា ៤.-**

គ.ជ.អ.ប មានការទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល អំពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

**មាត្រា ៥.-**

គ.ជ.អ.ប ត្រូវធានាឱ្យច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវបានអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធនានានៅថ្នាក់ជាតិ មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ៦.-**

គ.ជ.អ.ប ត្រូវធានាឱ្យគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់នានាមានសង្គតិភាពជាមួយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

**មាត្រា ៧.-**

គ.ជ.អ.ប អាចដោះស្រាយ ឬលើកសំណើសុំសេចក្តីសម្រេចពីរាជរដ្ឋាភិបាលលើការមិនចុះសម្រុងគ្នា ដែលអាចកើតមានឡើងទាក់ទងនឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

/Rh

**មាត្រា ៨.-**

អនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល មន្ទីរ អង្គភាពនានា និងក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិមានភារកិច្ចអនុវត្តសេចក្តីសម្រេចរបស់ គ.ជ.អ.ប។

**មាត្រា ៩.-**

ករណីក្រសួង ស្ថាប័នណាមួយរបស់រាជរដ្ឋាភិបាល មិនអនុវត្តតាមការសម្រេចរបស់ គ.ជ.អ.ប គណៈកម្មាធិការជាតិត្រូវរាយការណ៍ ដើម្បីសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល។

**មាត្រា ១០.-**

ករណីក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ មិនអនុវត្តតាមការសម្រេចរបស់ គ.ជ.អ.ប គណៈកម្មាធិការជាតិ ត្រូវស្នើដល់ក្រសួងមហាផ្ទៃដើម្បីអនុវត្តទៅតាមនីតិវិធីដែលបានកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

**មាត្រា ១១.-**

គ.ជ.អ.ប ត្រូវមានសញ្ញាសម្គាល់ និងមានត្រារបស់ខ្លួនដែលកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ គ.ជ.អ.ប។

## ជំពូកទី ៤
## របៀបរបបការងារ រចនាសម្ព័ន្ធ និងលេខាធិការដ្ឋាន

**មាត្រា ១២.-**

គ.ជ.អ.ប ត្រូវជួបប្រជុំសាមញ្ញរៀងរាល់ពីរ(០២)ខែម្តង។

គ.ជ.អ.ប អាចធ្វើការប្រជុំវិសាមញ្ញតាមការចាំបាច់ តាមការស្នើសុំរបស់ប្រធាន ឬសមាជិកយ៉ាងតិច១ភាគ៣ នៃសមាជិកទាំងមូលរបស់ គ.ជ.អ.ប។

គ.ជ.អ.ប ត្រូវរៀបចំ និងអនុម័តនូវរបៀបរបបការងារ និងបទបញ្ជាផ្ទៃក្នុងនៅក្នុងកិច្ចប្រជុំលើកទី១របស់ខ្លួន ។

**មាត្រា ១៣.-**

ត្រូវបង្កើតអនុគណៈកម្មាធិការ ដើម្បីធ្វើជាជំនួយការឱ្យ គ.ជ.អ.ប ដែលមានដូចខាងក្រោម

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

8/12

- អនុគណៈកម្មាធិការមុខងារ និងធនធាន
- អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ
- អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រៅពីអនុគណៈកម្មាធិការទាំងបី(០៣)ខាងលើ គ.ជ.អ.ប អាចស្នើសុំបង្កើតអនុគណៈកម្មាធិការផ្សេងៗទៀតជាជំនួយការ តាមការចាំបាច់។

**មាត្រា ១៤.-**

អនុគណៈកម្មាធិការនីមួយៗ ត្រូវដឹកនាំដោយប្រធានមួយ(០១)រូប អមដោយអនុប្រធានចំនួនពីរ(០២)រូប។

សមាសភាពអនុគណៈកម្មាធិការនៃ គ.ជ.អ.ប ព្រមទាំងរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការនីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ គ.ជ.អ.ប។

**មាត្រា ១៥.-**

អនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប ត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល ឬ/និង អ្នកពាក់ព័ន្ធនានាមុនពេលផ្តល់អនុសាសន៍ដល់ គ.ជ.អ.ប។

**មាត្រា ១៦.-**

អនុគណៈកម្មាធិការនីមួយៗ អាចបង្កើតក្រុមការងារមួយ ឬច្រើនតាមការចាំបាច់ ដើម្បីសិក្សា និងរាយការណ៍អំពីការងារដែលស្ថិតនៅក្នុងភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួន។ សមាជិកនៃក្រុមការងារនេះ អាចជ្រើសរើសចេញពីមន្ត្រីក្រសួង ស្ថាប័ននៃប្រធានអនុគណៈកម្មាធិការនោះ ឬអាចស្នើសុំមន្ត្រីពីក្រសួង ស្ថាប័នដែលមានតំណាងក្នុងអនុគណៈកម្មាធិការ ឬ/និង តំណាងពីអ្នកពាក់ព័ន្ធនានាតាមការសម្រេចរបស់អនុគណៈកម្មាធិការ។

**មាត្រា ១៧.-**

ក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវបង្កើតឱ្យមានក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការប្រចាំក្រសួង ស្ថាប័នខ្លួន ដើម្បីសម្របសម្រួល និងគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

គ.ជ.អ.ប អាចចេញសេចក្តីណែនាំអំពីកិច្ចដំណើរការនៃក្រុមការងារខាងលើនេះ តាមការចាំបាច់។

ROYAUME DU CAMBODGE · MINISTRE DU PALAIS ROYAL · ព្រះបរមរាជវាំង

**មាត្រា ១៨.-**

គ.ជ.អ.ប ត្រូវមានលេខាធិការដ្ឋានមួយស្ថិតនៅក្នុងទីស្តីការក្រសួងមហាផ្ទៃ។

លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវដឹកនាំដោយប្រធានមួយ(០១)រូប ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ អមដោយអនុប្រធានចំនួនបី(០៣)រូប ដែលមានឋានៈស្មើអគ្គនាយកជាជំនួយការដែលតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី តាមរយៈសេចក្តីស្នើសុំពី គ.ជ.អ.ប។

លេខាធិការដ្ឋានត្រូវបង្កើតឱ្យមានអង្គភាពនានាដែលកំណត់ដោយអនុក្រឹត្យ។

អង្គភាពនីមួយៗនៃលេខាធិការដ្ឋាន ត្រូវគ្រប់គ្រងដោយប្រធាន ០១រូប និងអនុប្រធានមួយចំនួនជាជំនួយការដែលតែងតាំងដោយអនុក្រឹត្យ។

ប្រធានអង្គភាពត្រូវមានឋានៈស្មើអគ្គនាយករង អនុប្រធានអង្គភាពត្រូវមានឋានៈស្មើប្រធាននាយកដ្ឋាន។

**មាត្រា ១៩.-**

លេខាធិការដ្ឋាន ត្រូវបំពេញរាល់កិច្ចការចាំបាច់នានា ដើម្បីធានាឱ្យ គ.ជ.អ.ប បំពេញមុខងាររបស់ខ្លួនបានសមស្រប និងមានប្រសិទ្ធភាព ព្រមទាំងជួយជាជំនួយបច្ចេកទេស និងលេខាធិការដល់អនុគណៈកម្មាធិការនីមួយៗ។

លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ គ.ជ.អ.ប ។

## ជំពូកទី ៥
## ប្រភពធនធានថវិកា

**មាត្រា ២០.-**

គ.ជ.អ.ប ត្រូវមានថវិការបស់ខ្លួន ដើម្បីបំពេញការងារដែលសមស្របនឹងតម្រូវការនានាដែលមានចែងនៅក្នុងកម្មវិធីជាតិ និងតម្រូវការនានាសម្រាប់អនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

ថវិការបស់ គ.ជ.អ.ប ត្រូវស្ថិតក្នុងខ្ទង់មួយដោយឡែក ក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

10/12.

**មាត្រា ២១.-**

គ.ជ.អ.ប អាចទទួលជំនួយផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងសម្ភារៈពីប្រភពក្នុងប្រទេស និងក្រៅប្រទេស សម្រាប់អនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

## ជំពូកទី ៦
## អន្តរប្បញ្ញត្តិ

**មាត្រា ២២.-**

ក្នុងរយៈពេលដែលមិនទាន់មានលេខាធិការដ្ឋាននៃ គ.ជ.អ.ប តាមស្មារតីនៃព្រះរាជក្រឹត្យនេះ លេខាធិការដ្ឋាននៃ គ.ជ.វ.វ ត្រូវបន្តការងារជាលេខាធិការដ្ឋាននៃ គ.ជ.អ.ប។

**មាត្រា ២៣.-**

គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង និងគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង ត្រូវបន្តធ្វើជារចនាសម្ព័ន្ធ និងប្រព័ន្ធគាំទ្ររបស់គ.ជ.អ.ប នៅរដ្ឋបាលថ្នាក់ក្រោមជាតិរហូតដល់មានការរៀបចំជាថ្មី។

**មាត្រា ២៤.-**

រាល់កិច្ចការដែលសេសសល់ពី គ.ជ.វ.វ រួមទាំងសេចក្តីសម្រេចនានា ផែនការសកម្មភាព និងថវិកា គម្រោង កម្មវិធី និងកិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា គ.ជ.អ.ប ត្រូវបន្តសម្របសម្រួលអនុវត្តអោយបានសមស្រប និងមានប្រសិទ្ធភាព។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**មាត្រា ២៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

មាត្រា ២៦.-

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសមាសភាពដូចមានចែងក្នុងមាត្រា ២ខាងលើ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨

៣រល.០៨១២.១៤៤៩ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ : ០៥ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ស៊ុន ជិនកេន**

12/12

# ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១៤៣០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពី ការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា"
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពី ការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពី ការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា" ឱ្យស្របជាមួយបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពី លក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពី ការកែសម្រួលមាត្រា៤ និង មាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពី ការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពី ការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា"
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំង ឯកឧត្តម **ហង់ ពៅ** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានអាជ្ញាធរអប្សរា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបាន សម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*៣រ៧.០៧១២.១៤៥០*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨*

លេខ : ០៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ០១ ឆ្នាំ២០០៩

**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០០១

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងពត៌មាន
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានតែងតាំងទីប្រឹក្សាក្រសួងពត៌មានដូចមានរាយនាមខាងក្រោម:

១-ឯកឧត្ដម **យឿន នារ៉ា** មានឋានៈស្មើ អគ្គនាយក

២-ឯកឧត្ដម **មួង សុវត្ថិ** មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២ :** សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ។

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**

**នរោត្ដម សីហមុនី**

៣.ល.០១០១.០០១

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៩*

លេខ : ១០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ប៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០០២

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: ត្រូវបានតែងតាំងលោកជំទាវ **លី ឡុចឡេង** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា និងជាអនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ មានឋានៈស្មើ រដ្ឋមន្ត្រី ។

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣**: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

៣៧.០១០១.០០២

លេខ : ១១ ច.ល

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៩*

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមករា ឆ្នាំ២០០៩
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០០៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងទីប្រឹក្សាក្រសួងផែនការដូចមានរាយនាមខាងក្រោម:

១-ឯកឧត្តម **សេង ស៊ឿន** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

២-ឯកឧត្តម **ខៀវ សារី** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៣-ឯកឧត្តម **ទី ហៀង** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៤-ឯកឧត្តម **សាង សម** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧.០៩០១.០០៣

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៩*

លេខ : ០៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០០៩
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**ប្រការ ១ :** តែងតាំងមន្ត្រីរាជការ ចំនួន ១០ រូប នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដូចមានរាយនាមខាងក្រោម:

១- ឯកឧត្តម **ទូន ថាវរៈ** ជាសមាជិក ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២- ឯកឧត្តម ចាន់ សុធី ជាសមាជិក ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

៣- ឯកឧត្តម ឈន សុភាព ជាអគ្គលេខាធិការរង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៤- ឯកឧត្តម គីម សុភៈ ជាអគ្គលេខាធិការរង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

៥- ឯកឧត្តម អៀង ស៊ុនលី ជាជំនួយការ ឯកឧត្តមប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន

៦- ឯកឧត្តម ម៉ី វ៉ាន់ ជាជំនួយការ ឯកឧត្តមប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន

៧- ឯកឧត្តម ហែម វណ្ណឌី ជាជំនួយការ ឯកឧត្តម សុន គន្ធរ អនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន

៨- លោកជំទាវ ហេង សុគន្ធ ជាជំនួយការ ឯកឧត្តម ឈៀង យ៉ាណារ៉ា អនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន

៩- ឯកឧត្តម នេត មុន្នី ជាជំនួយការ ឯកឧត្តម ជូ វិជិត្ត សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន

១០- ឯកឧត្តម ហៃល ចំរើន ជាប្រធានផ្នែកសិក្សា និងវិភាគគោលនយោបាយ អភិបាលកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២:** តម្លើងឋានៈស្មើ អគ្គនាយក ជូនមន្ត្រីរាជការ នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម សុខ សារ៉ាវុឌ្ឍ ជំនួយការឯកឧត្តមប្រធានឧត្តមក្រុមប្រឹក្សសេដ្ឋកិច្ចជាតិ

២-ឯកឧត្តម កែន សម្បត្តិ ជំនួយការឯកឧត្តម ជូ វិជិត្ត សមាជិកឧត្តមក្រុមប្រឹក្សសេដ្ឋកិច្ចជាតិ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រ៧.០៩០១.០០៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០៩

លេខ : ០៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងកិច្ចការនារី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានតែងតាំងលោកជំទាវ ខៀវ សិរីវុទ្ធណ្ណា ជា អគ្គនាយក នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី ។

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៩៧.០១០១.០០៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៩

លេខ: ១៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមករា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៤ នៃរដ្ឋសភា នាថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំរដ្ឋសភា និងសំដែងការទុកចិត្តទៅលើសមាសភាព រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

*មាត្រា១* .- ត្រូវបានតែងតាំងជាទីប្រឹក្សា ឯកឧត្តម **ងួន ញ៉ិល** អនុប្រធានទី១ រដ្ឋសភា នីតិកាលទី៤:

**១-ឯកឧត្តម ឡេង ចន្ថា មានឋានៈស្មើ អនុរដ្ឋលេខាធិការ**

**២-ឯកឧត្តម ជាំ គីមហាន មានឋានៈស្មើ អគ្គនាយក ចំណែកលើមុខងារបច្ចុប្បន្ន**

*មាត្រា២* .- សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

*មាត្រា៣* .- ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

*៣៧ល.០៩០១.០០៦*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៩*

លេខ : ១៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០០៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម កែវ ពុទ្ធរស្មី ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ឧបនាយករដ្ឋមន្ត្រី ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៤៧.០៩០១.០០៧

លេខ : ០៣ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៩

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមករា ឆ្នាំ២០០៩
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ស៊ុន ជិនគេន